គង់ សម្ភារ

# ទស្សនៈ
# សម្ដេចព្រះសង្ឃរាជ
# ជួន ណាត

ព.ស. ២៥១៣ គ.ស. ១៩៧០



សម្តេចព្រះមហាសុមេធាធិបតី

ព្រះសង្ឃរាជ គណៈមហានិកាយ

ជួន.ណាត ជោតញ្ញាណោ

## អារម្ភកថា
## សូមគោរពព្រះវិញ្ញាណក្ខន្ធនៃសម្តេច
## ព្រះសង្ឃរាជជាអម្ចាស់

## អ្នកអានជាទីមេត្រី!

សៀវភៅ «ទស្សនៈ សម្តេចព្រះសង្ឃរាជ ជួន-ណាត» ដែលព្រះអង្គ អស់លោកអ្នកនាងកំពុងអាននេះ ខ្ញុំបានប្រមូលចងក្រងចេញពីព្រះរាជនិពន្ធជាច្រើន របស់ សម្តេចព្រះមហាសុមេធាធិបតីជោតញ្ញាណោ ជួន-ណាត ព្រះសង្ឃរាជថ្នាក់ទី ១ ដែលព្រះអង្គនិពន្ធក្នុងច្បាប់នានា។

ខ្ញុំយល់ឃើញថា «ទស្សនៈសម្តេចព្រះសង្ឃរាជ ជាទស្សនៈមិនស្លាប់» មានអានុភាពច្រើនក្នុងការដឹកនាំសតិអារម្មណ៍របស់ក្រុមពុទ្ធបរិស័ទឲ្យធ្វើដំណើរទៅរកពន្លឺនៃសុភមង្គល។

មិនតែប៉ុណ្ណោះ ទស្សនៈនេះពិតជាមានផលប្រយោជន៍ច្រើនដល់អស់លោកនិស្សិត សិស្សានុសិស្សដែលប្រុងប្រៀបប្រឡងយកសញ្ញាប័ត្ររបស់ខ្លួនជាពិសេសចំពោះអ្នកស្រាវជ្រាវទូទៅ ព្រោះអត្ថបទទាំងនេះសុទ្ធសឹងមាន

អត្ថន័យ អត្ថរស អត្ថរូប កម្រនឹងរកគួដែនិពន្ធមកប្រដូចបាន ហើយជាឯកសារពិបាករកទៀតផង នាអនាគតកាល។

ខ្ញុំដឹងយ៉ាងច្បាស់ថា ឯកសារទាំងនេះគឺជាវត្ថុដ៏មានតម្លៃដល់បេក្ខជនធ្វើនិក្ខេបបទ ប្រឡងយកសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ ដែលស្ដីអំពីព្រះសង្ឃរាជ ជាទីសក្ការៈនៃយើងមិនខាន។

ដោយខ្ញុំយល់ឃើញដូច្នេះហើយទើបខ្ញុំតស៊ូស្វែងរកឯកសារទាំងនេះ ពីកន្លែងមួយទៅកន្លែងមួយ រហូតបានសម្រេចបំណង ព្រោះខ្ញុំខ្លាចភ្លើងឆេះ ឬចិនលក់នំប៉័ងខ្ចប់នំឲ្យយើងបរិភោគ។ (សុ.ស.ហ.ស.រ)

ការប្រមូលចងក្រងនេះ ខ្ញុំមានចិត្តបារម្ភណាស់ក្រែងមានខុសឆ្គងដោយអន្លើណាមួយ។ មុននឹងធ្វើខ្ញុំបានក្រាបបង្គំសួរយោបល់ពីសំណាក់ព្រះសង្ឃដែលមានចំណេះដឹងខ្ពស់ខ្ពស់ដូចជា ព្រះវិរិយបណ្ឌិតោ ភិក្ខុ ប៉ាង -ខាត់ សាស្ត្រាចារ្យរបស់ខ្ញុំ ព្រះអង្គក៏មានថេរដីកាមកកាន់ខ្ញុំថា «ល្អហើយចៅ! ការនេះប្រពៃណាស់! បើចៅមានគំនិតយ៉ាងនេះ គួរប្រញាប់ធ្វើភ្លាមៗទៅ ដើម្បីឲ្យទាន់ពេលវេលា . . . លោកតាជួយអរ ហើយជាកិច្ចតបស្នងរបស់ចៅផងចំពោះព្រះអង្គ . . . !» ព្រះថេរដីកានេះធ្វើឲ្យបេះដូងខ្ញុំរំភើបកក្រើកក្រៃលែង។ ខ្ញុំក៏ក្រាបថ្វាយបង្គំលាដោយចិត្តសោមនស្សក្រៃលែង ហើយក្នុងពេលនោះលោកតាបានប្រទាននូវសៀវភៅដ៏សំខាន់របស់លោកមួយ «កើតទៀតឬទេ?» ដល់ខ្ញុំទៀតផង។ ការធ្វើនេះខ្ញុំស្ទើរតែជៀសវាងនូវការអធិប្បាយផ្សេងៗ ដើម្បីទុកឲ្យអ្នកអានពិចារណាផងចុះ។

លុះធ្វើចប់ហើយ ខ្ញុំបានយកទៅប្រគេនព្រះតេជគុណ។

ព្រះមុនីកោសល សូរ-ហាយ សូមឲ្យព្រះថេរៈអង្គនេះជួយពិនិត្យកែសម្រួល ក្រែងលោខ្ញុំយល់ច្រឡំឬភ្លាំងភ្លាត់ត្រង់វគ្គណា។ ពេលនោះព្រះអង្គបានយល់ព្រមជួយកិច្ចកុសលនេះ ដោយហឫទ័យសោមនស្សក្រៃលែង ថ្វីបើកិច្ចការលោកច្រើនឥតគណនាក៏ដោយ ចំពោះអំពើដ៏សប្បុរសនៃព្រះមុនី

កោសល ធ្វើឲ្យបេះដូងខ្ញុំរំភើបជាអតិបរមា ដោយនឹកឃើញថា «ជីវិតខ្ញុំក្នុងជាតិនេះតែងបានទទួលការប្រោសប្រណីពីសំណាក់ព្រះសង្ឃរាជជាដរាបតាំងពីកុមារភាព! ឱព្រះគុណដ៏ធ្ងន់! ដ៏ប្រសើរអើយ . . . !» មកតែពីព្រះគុណដ៏សម្បើមនេះហើយ ទើបធ្វើឲ្យចិន្តាខ្ញុំចាប់ប្រមូលចងក្រង «ទស្សនៈសម្តេចសង្ឃរាជ» ជាអម្ចាស់នេះឡើង ដើម្បីតបស្នងសងព្រះគុណព្រះអង្គ ដែលតែងតែយកព្រះហឫទ័យទុកដាក់មកលើយុវជន សិស្សានុសិស្សសំណាក់ក្នុងវត្តនិងទីដទៃទៀត។

មួយចំណែកទៀត ខ្ញុំសូមអរគុណចំពោះព្រះតេជព្រះគុណរាល់អង្គ និងកល្យាណមិត្តទាំងអស់ ដែលបានផ្តល់ឯកសារព្រមទាំងយោបល់ខ្លះៗផងមកខ្ញុំ។

ជាពិសេសខ្ញុំសូមថ្លែងនូវសេចក្តីដឹងគុណដ៏ជ្រាលជ្រៅ ចំពោះបង ហាក់-ផល្លា, បង គង់-សាឯម, និងអ្នក គង់-រ៉យ ដែលតែងតែជួយប្អូនគ្រប់ពេលវេលាក្នុងកិច្ចសិក្សា ហើយក្នុងពេលនេះទៀត បងបានឧបត្ថម្ភប្អូនគ្រប់បែបយ៉ាង រហូតធ្វើឲ្យសៀវភៅ «ទស្សនៈសម្តេចព្រះសង្ឃរាជ» នេះបានប្រសូតឡើង។ ការនេះបើកុំតែមានបង មុខជាប្អូនមិនបានតបព្រះករុណាទិគុណព្រះរាជានៃអក្សរសាស្ត្រជាដាច់ខាត។

ម៉្យាងវិញទៀត ខ្ញុំក៏មិនភ្លេចដែរ នូវសន្តានចិត្តដ៏សប្បុរសនៃ ព្រះឧបជ្ឈាយ៍ ង៉ែត-មិន, ព្រះវិន័យធរ គង់-សុមឿន, លោក អ៊ំ-គង់សូត, អ្នកមីងហេង និងអស់លោកឯទៀតដែលអាណិតនិងជួយខ្ញុំ ទោះបីផ្លូវចិត្តក្តី ផ្លូវទ្រព្យក្តី។

កុសលដែលកើតអំពីសៀវភៅទស្សនៈនេះកូនទាំងអស់ សូមឧទ្ទិសជូនចំពោះវិញ្ញាណក្ខន្ធ លោកឪពុកនាម គង់-ស្វាយ និងអ្នកម្តាយនាម មាស-ម៉ៅ ដែលបានធ្វើមរណកាលដ៏យូរលង់ហើយ សូមលោកទាំងពីរបានប្រកបដោយសេចក្តីសុខក្សេមក្សាន្តក្នុងសុគតិភពកុំបីខាន។

ចំណែកខ្ញុំ, ខ្ញុំសូមកុំឲ្យកើតមកកំព្រីកំព្រា, ល្ងង់ខ្លៅ, ខ្វះភារតភាព និង សូមឲ្យមនុស្សទួទៅអាណិត រាប់អានគ្រប់ៗ!ជាត់; ជាពិសេសក្នុងជាតិនេះតែម្ដង។

សូមអរគុណ!

ដំណាក់មនោរម្យ ថ្ងៃទី២០ កុម្ភៈ ព.ស. ២៥១៣
គ.ស. ១៩៧០

**គង់ - សម្ភារ**

សមាជិកគណៈកម្មការឃោសនាការ
នៃពិធីបុណ្យព្រះបរមសព

## វិចារណកថា
## ប្រាំបួនទ័ល ដប់ទ័ល កុំឲ្យតែទ័លគំនិត

១ – សូមសេចក្ដីប្រាថ្នា របស់សាធុជនស្រីប្រុសបានសម្រេចផលតាមបំណង ដែលបានធ្វើបុណ្យឧទ្ទិសថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះសង្ឃរាជព្រះនាម ជួន-ណាត។

២ – ទស្សនៈនៃសម្ដេចព្រះសង្ឃរាជនេះ បើកម្លោជិកណាមួយបានអានហើយ នឹងផ្ដល់នូវសេចក្ដីអង់អាចក្លាហានស្រលាញ់ការសិក្សា ឬ ប្រកបកិច្ចការទាំងពួងមិនខាន។

៣ – សម្ដេចព្រះសង្ឃរាជ មិនមែនជាអ្នកប្រាជ្ញខាងអក្សរសាស្រ្តមួយមុខទេ តាមពិតព្រះអង្គជាអ្នកប្រាជ្ញច្រើនមុខ (ពហុវិជ្ជា)។

៤ – ការចេះដឹងនៃព្រះអង្គ គឺជាការចេះដឹងទាំងពីរផ្លូវ ដែលរកបុគ្គលណាមួយក្នុងសតវត្សនេះប្រៀបផ្ទឹមពុំបាន សូម្បីទេវតាក៏ក្រាបថ្វាយបង្គំព្រះអង្គដែរ។

៥ – អ្នកប្រាជ្ញ សូម្បីរាងកាយទ្រុឌទ្រោមជិតដល់នូវមរណភាពហើយក៏ដោយ លោកក៏មិនព្រមបោះបង់ការងារដ៏ប្រសើររបស់លោកឡើយ ព្រោះលោកយល់ច្បាស់ថា សេចក្ដីស្លាប់ជាធម៌ទៀង។

៦ – ផ្លូវដែលសម្ដេចទ្រង់យាង គឺតាមព្រះមាគ៌ានៃព្រះពុទ្ធជាម្ចាស់ឥតខ្ចោះ។

៧ – ការសោយព្រះទិវង្គតនៃសម្ដេច ប្រៀបបាននឹងការរលត់នៃដួងព្រះអាទិត្យនិងព្រះចន្ទ។

៨ – អ្នកប្រាជ្ញច្រើនរូបបានពោលថា " សម្ដេចព្រះសង្ឃរាជ បានយាងចូលព្រះទិវង្គតក្នុងសម៌ភូមិ " ខ្លះទៀតថា " ការសោយព្រះទិវង្គតនៃព្រះអង្គប្រៀបបាននឹងដាច់ចរន្តអគ្គិសនី " ។

៩ – មែនពិត អ្នកប្រាជ្ញរមែងគិតចំពោះសេចក្តីលំបាករបស់អ្នកផង សូម្បីដឹងថារូបអាត្មាអញ ត្រូវម្រឹត្យុចាប់ទាញព្រលឹងឥឡូវនេះហើយ ក៏លោកមិនប្រាប់គេ ព្រោះខ្លាចគេលំបាកដោយសារខ្លួនលោក។

១០ – ការសោយព្រះទិវង្គតនៃសម្តេច បានធ្វើឲ្យផែនដីកម្ពុជានេះរញ្ជួយឥតឧបមា។

១១ – បណ្ឌិតកាលមានជន្មរស់នៅ មិនសូវញុំាងចិត្តអ្នកផងឲ្យគោរពកោតខ្លាចស្ងប់ស្ងែងប៉ុន្មានទេ លុះដល់រលត់សង្ខារ សូម្បីតែសត្រូវលោកក៏ចុះចាញ់ គោរពគុណធម៌របស់លោកដែរ កុំនិយាយឡើយពីជនសាមញ្ញ។

១២ – មានប្រយោជន៍អ្វីក្នុងការបួសហើយមិនសិក្សានូវវិជ្ជាផ្លូវលោក ផ្លូវធម៌ និងមិនគោរពតាមព្រះពុទ្ធឱវាទផង? ដូចជនពុករលួយ មានប្រយោជន៍អ្វី? បានគ្រាន់តែចង្អៀតសង្គមនិងខូចកិត្តិយសសង្គមប៉ុណ្ណោះ។

១៣ – អ្នកណាបួសហើយ ដឹកនាំគេឲ្យស្គាល់ផ្លូវល្អអាក្រក់ ពោលគឺបានសិក្សាគម្ពីរដីកានូវវិជ្ជាផ្សេងៗ ហើយប្រព្រឹត្តិត្រឹមត្រូវល្អ អ្នកនោះទើបឈ្មោះថា អ្នកបួសត្រូវតាមសមណភេទ . . . ព្រោះថា ព្រះពុទ្ធសាសនាដែលរុងរឿងទៅកើតមកពីអ្នកបួស បើអ្នកដឹកនាំឱនថយសាសនាក៏ចុះតាមនោះដែរ ដោយហេតុថា របស់អ្វីក៏ដោយក្នុងលោកនេះដែលមនុស្សមិនបង្កើត?

១៤ – ឱ ក្មួយកំសត់អើយ! អ្នកមិនទាន់បានរៀនសូត្រសោះ កើតក្នុងសម័យអក្សរសាស្ត្រយើងផុសឡើងវិញនេះ រាត្រីទាំងឡាយចេះតែធ្វើគមនាការជានិច្ច រូបអ្នកនឹងនៅក្នុងហ្វូងអនក្ខរជន ប្រៀបដូចជានៅក្នុងគុហាងងឹតសូន្យសុង។

កាលបើយើងគិតឃើញដូច្នេះហើយ យើងគួរនាំគ្នាបង្ហាត់បង្ហាញកូនក្មួយក្នុងពេលឥឡូវនេះទៅឲ្យសមតាមព្រះរាជបំណងនៃ សម្តេចព្រះបិតាឯករាជ្យជាតិយើង ដែលព្រះអង្គមានព្រះរាជហឫទ័យ ចង់ឲ្យកូនខ្មែរចេះអក្សរគ្រប់ៗគ្នា ព្រោះថា៖

១៥ – កូនមានគុណគាប់តែម្នាក់ជាកូនប្រសើរ កូនល្ងង់រាប់រយមិនប្រសើរទេ ដូចព្រះចន្ទតែមួយដួងអាចកំចាត់ងងឹតអន្ធការបានកងតារាទាំងឡាយ កំចាត់ងងឹតមិនបានឡើយ[១]។

១៦ – បណ្ដាកូនបីពួក គឺកូនមិនទាន់កើតមួយពួក កូនកើតហើយស្លាប់ទៅវិញមួយពួក និង កូនល្ងង់មួយពួក កូនពីរពួកខាងដើមជាកូនគាប់ប្រសើរ , ពួកកូនទីបីមិនប្រសើរឡើយ ព្រោះថា កូនពីរពួកខាងដើម ធ្វើទុក្ខព្រួយ តែម្ដងក៏អស់ទៅហើយ ឯពួកកូនក្រោយទីបីធ្វើទុក្ខមាតាបិតាឲ្យលំបាកគ្រប់ជំហានជើង[២]។

១៧ – ការកើតឡើងនៃមនុស្សងាយណាស់ តែការធ្វើខ្លួនឲ្យទៅជាមនុស្សម្នាក់នឹងគេ មិនងាយទេ តោងប្រឹងប្រែងព្យាយាមទើបបានសម្រេច។

១៨ – ការម្សៀសគេធ្វើសម្រាប់ដាក់សព។ រីឯសុភមង្គលសម្រាប់តែជនណា ដែលចេះក្រេបជញ្ជក់គ្រប់កាលៈទេសៈ។

១៩ – អ្នកធ្វើខ្ញុំបំរើគេ តែងធន់ទ្រាំលំបាកដោយត្រជាក់ដោយខ្យល់និងដោយកំដៅថ្ងៃ ឥតបានប្រយោជន៍អ្វីសោះ, ឯអ្នកប្រាជ្ញខំបំពេញតបៈ បើទុកជាលំបាកគង់បានសេចក្ដីសុខជាផល[៣]។

២០ – ការតាំងខ្លួនមិនឲ្យជាខ្ញុំគេ តែងបានផលជាសុខដល់ជីវិត, បើជនណា ព្រមនៅក្នុងអំណាចគេ ជននោះឈ្មោះថាមានជីវិតរស់ ដូច្នោះតើជនបែបណាវិញហ្ន៎ ដែលឈ្មោះថាស្លាប់?[៤]

២១ – ជនអប្បឥតប្រាជ្ញា សំរាំងខ្លួនហើយសំរាំងទៀត ទុកបំរុងគ្រាន់តែបម្រើជនដទៃជានាយ ព្រោះប្រាថ្នាទ្រព្យ ដូចស្ត្រីផ្កាមាស តុបតែងខ្លួនឲ្យល្អទុកសម្រាប់តែបុរស។[៥]

២២ – ព្រះពុទ្ធជាម្ចាស់ជួយយើងបាន លុះណាតែយើងជួយខ្លួនយើង

---

១ + ២ ៖ ស្រីហិតោបទេស ភាគ១ របស់ព្រះភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ។

៣ +៤+៥ ៖ ស្រីហិតោបទេស ភាគ២ របស់ព្រះភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ។

ផង។

២៣ – ការដែលគេមកសុំសន្លឹកឆ្នោតពីយើង គេលុតជង្គង់ដល់ធរណី ព្រោះតែគេចង់ស៊ីថ្លើមយើង ហើយដល់គេបានសន្លឹកឆ្នោតហើយ គេដាក់ធរណីបោលលែងមកក្បែរយើងទៀត តើយើងត្រូវធ្វើដូចម្ដេចហ្ន៎ឲ្យបានដូចបំណង?

២៤ – មនុស្សមិនត្រូវអួតថា គ្មាននរណាបោកបានមួយជីវិតទេ តែត្រូវគិតកុំឲ្យគេបោកបានច្រើនដងពេក។

២៥ – ការជ្រើសរើសអ្នកតំណាងយើងពិបាកជាងការរើសកូនប្រសាត្រីភាគ មិនដូចល្បង់ពោលថា បោះឲ្យនរណាក៏ដូចនរណាដែរនោះទេ ..... ព្រោះថា អាយុជីវិតនៃប្រទេសជាតិត្រូវផ្ញើនៅលើអ្នកតំណាងរបស់ផងយើងមួយផ្នែកធំ មិនគួរយើងយកសំបកគ្រំមកទះលេងនោះទេ។

២៦ – ការដែលគេឲ្យយើងស៊ី មកតែគេចង់ស៊ីពីយើង។

២៧ – អ្នកប្រាជ្ញឆោតនៅក្រៅទីប្រជុំអួតក្អេងក្អាងណាស់ សូម្បីតែព្រះក៏គេហ៊ានចោទឆ្លើយដែរ តែតាមពិតនៅទីជំនុំ សូម្បីតែដៃស្ទើរតែមិនហ៊ានលើកផង កុំនិយាយឡើយទៅជជែកវែករកការខុសត្រូវ! តើយើងត្រូវជ្រើសរើសជនប្រភេទណា ឲ្យធ្វើជាភ្នែកច្រមុះរបស់ផងយើង?

២៨ – អ្នកប្រាជ្ញតែងណែនាំយុវជនឲ្យបែរមុខទៅរកសេចក្ដីចំរើន មិនដែលណែនាំឲ្យមនុស្សទៅរកសេចក្ដីវិនាសទេ សូម្បីតែសត្រូវរបស់លោក ក៏លោកនៅតែប្រោសប្រណីជានិច្ច ដូចមហាត្មៈគន្ធី ជាអាទិ៍។

២៩ – សម្ដេចព្រះសង្ឃរាជជាម្ចាស់ ទ្រង់សោយព្រះទិវង្គតមែនពិត តែព្រះឧត្ដមគតិនៃព្រះអង្គនៅរស់រវើកជានិច្ច ហើយរឹងរឹតតែលេចឮគ្រប់ទិសមើលទៅសូម្បីព្រះឥន្ទ្រក៏ស្ងើចសរសើរដែរ កុំថាឡើយតែអ្នកប្រាជ្ញសកលលោក។

៣០ – សេចក្ដីល្អរបស់ព្រះអង្គ តែងប្រោសប្រណីមកដល់ទូលព្រះបង្គំ

យើងខ្ញុំករុណា បានធ្វើឲ្យបេះដូងខ្ញុំព្រះអង្គស្រពាប់ស្រពោននឹកព្រះអង្គលុះក្ស័យសង្ខារ។

៣១ – វត្តជាស្ថានមនោរមផង ! ជាកន្លែងព្យាបាលរោគល្ងង់ខ្លៅផង ! ជាកន្លែងដោះទុក្ខសត្វកំព្រាតោកយ៉ាកផង និងជាកន្លែងរៀបចំកម្មវិធីទៅកាន់ឋាននិព្វានផងនៃសត្វលោកទូទៅ។

៣២ – ព្រះពុទ្ធសាសនា មានតម្លៃរកប្រមាណមិនបានឡើយ, ព្រោះបានបង្រៀនមនុស្សឲ្យស្គាល់ប្រភពនៃសេចក្ដីសុខ សេចក្ដីទុក្ខគ្រប់យ៉ាង ... ។

៣៣ – សេចក្ដីប្រាថ្នារបស់ខ្ញុំមានតែម្យ៉ាងទេគឺៈ សុំឲ្យអ្នកផងអាណិតមេត្តា ទោះបីដើរទៅទីណាក៏កុំឲ្យមានឧបសគ្គរាំងរា លែងកំព្រាតោកយ៉ាកក្នុងទីនោះទៀត !

៣៤ – មុននឹងគេបោកមនុស្សណាម្នាក់ គេតែងធ្វើល្អនឹងអ្នកនោះមុនជាដរាប។

៣៥ –គ្រាន់តែឃើញជនដែលធ្វើល្អភ្លាម កុំអាលសរសើរថា ជាមនុស្សត្រឹមត្រូវ តាមពិតជនពុករលួយក៏វាចេះធ្វើបុណ្យហែកឋិនដែរ ដើម្បីបំបាំងអំពើពុករលួយរបស់វា, ដូច្នេះត្រូវពិចារណាឲ្យល្អិតល្អន់សឹមដាក់ជំនឿ។

៣៦ – ជនខ្លះយកសាសនាធ្វើជារនាំងដើម្បីបោកបញ្ឆោតយើងផង ! ធ្វើពាណិជ្ជកម្មផង លាក់កំហុសផង។

៣៧ –ជនកំហិល គេធ្វើជាឈរឈ្មោះកសាងវត្តអារាម តាមពិតបែរជាយកទីនោះធ្វើចេតិយឬម៉ុងសម្រាប់កប់ខ្មោចគ្រួសារគេសោះ សូម្បីតែចន្លោះធ្វើផ្លូវដើរក៏គ្មានដែរ !

៣៨ – បើយើងអាណិតស្រឡាញ់សាលាដំបូង ហើយស្អប់ខ្លួនយើងមានរឿងអ្វីបន្តិចបន្តួចនាំគ្នាប្ដឹងផ្ដល់ចុះ កុំខ្ចីស្ដាប់បុរាណភាសិតឡើយ។

៣៩ – គណៈកម្មការជាតិបានលើកព្រះអង្គ ជាព្រះអង្គមគ្គុទ្ទេសក៍ដ៏ផ្ទើម ក្នុងការណែនាំបកប្រែពាក្យខ្មែរ ព្រះអង្គទ្រង់បានជួយបកប្រែពាក្យខ្មែរ

តាំងពីដើមកំណើតខេមរយានកម្មម្ល៉េះ . . . (គ.ខ) ។

៤០ – ព្រះអង្គបានគាំទ្រជាទីបំផុត ចំពោះអង្គការខេមរយានកម្មសិក្សា ក្រៅពីព្រះយោបល់និងការបកប្រែពាក្យខ្មែរ ព្រះអង្គបានផ្តល់អត្ថបទជាច្រើន មកអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃខេមរយានកម្ម ដើម្បីលើកស្ទួយភាសាជាតិ និងទស្សនាវដ្តីខេមរយានកម្មឲ្យមានពន្លឺត្រចះត្រចង់គ្រប់ពេលវេលា . . . (គ.ខ) ។

៤១ – បើយើងសោកស្តាយព្រះអង្គ ស្រលាញ់ព្រះអង្គ ត្រូវគោរពព្រះអង្គដោយប្រតិបត្តិតាមព្រះឱវាទ ឬទស្សនៈព្រះអង្គកុំបីឃ្លាត !

៤២ – សម្តេចព្រះសង្ឃរាជ **ជួន.ណាត** ជាព្រះអង្គមហាបណ្ឌិតមួយព្រះអង្គក្នុងសតវត្សទី ២០ ។

៤៣ – ក្នុងពេលរស់នៅ ត្រូវខំប្រឹងធ្វើការ ដែលមានប្រយោជន៍ កុំសំចៃកម្លាំងទុកឡើយ ព្រោះកម្លាំងនោះបើឲ្យនៅស្ងៀមគង់តែត្រូវរិលរេចថយចុះរាល់ពេលដោយអំណាចជរា។ (សម្តេច ហួត.តាត)

៤៤ – បុគ្គលខ្វះសតិសម្បជញ្ញៈ រមែងស្រវឹងនៅក្នុងលោក ជាប់ចិត្តនៅក្នុងលោក មិនចង់រើខ្លួន ចេញចាកលោកនេះឡើយ (ព្រះមុនីកោសល សូរ.ហាយ) ។

៤៥ – អ្នកប្រាជ្ញតែងព្យាយាមបង្កើតសាមគ្គីធម៌គ្រប់ឥរិយាបថ (ព្រះមុនីកោសល សូរ.ហាយ) ។

៤៦ – ពុទ្ធវចនៈ ជាមាតាទស្សនវិជ្ជា, ជាមាតាសីលធម៌, ជាមាតានយោបាយ, ជាមាតាសេដ្ឋកិច្ច និងជាមាតាវិទ្យាសាស្ត្រ . . . សម្រាប់មនុស្សទូទៅ។

៤៧ – ទស្សនៈនេះមានន័យថា ការបង្ហាញប្រយោជន៍ ការចង្អុលគ្រោះថ្នាក់, ការអប់រំសីលធម៌និងការណែនាំមនុស្ស ឲ្យទៅរកត្រើយនៃសុភមង្គល ក៏ថាបាន។

# ទស្សនៈ ខេមរយានកម្មសិក្សា

ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះកិច្ចដឹកនាំដ៏ឈ្លាសវៃនៃសម្ដេចព្រះប្រមុខរដ្ឋ ប្រទេសខ្មែរមានភ័ព្វសំណាងខ្ពស់ខ្ពស់បានទទួលឯករាជ្យវប្បធម៌រឹងរឹតតែច្បាស់លាស់ថែមទៀត ពិសេសក្នុងវិស័យសិក្សាធិការជាតិចាប់តាំងពីកំណើតខេមរយានកម្មសិក្សាមក។ ជំហរវប្បធម៌ជាតិ ពឹងផ្អែកមួយផ្អែកធំទៅលើអក្សរនិងភាសាខ្មែរ ក៏ដូចជាពឹងផ្អែកទៅលើខេមរយានកម្មនេះដែរ ដោយសារតែខេមរយានកម្មនេះ ត្រូវចាត់ទុកដូចជាយានផ្ទុកយកចំណេះបរទេស មកលាតត្រដាងផ្សព្វផ្សាយជាភាសាខ្មែរឲ្យជ្រាបដល់ជម្រៅមជ្ឈដ្ឋានមិនត្រឹមតែសិស្សានុសិស្ស គ្រូបាធ្យាយប៉ុណ្ណោះទេ ថែមទាំងដល់ប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់វ័យថែមទៀតផង។ តាមជំនឿជ្រះថ្លាពេញលក្ខណៈ លើតម្លៃនិងមធ្យោបាយភាសាជាតិ ខេមរយានកម្មសិក្សាប្រាកដជាអាចបម្រើការរៀននិងការបង្រៀនគ្រប់ភូមិសិក្សាទាំងទាបទាំងខ្ពស់ បានទាំងអស់។

ភាសាជាតិណាក៏ដូចជាភាសាជាតិណាដែរ តែងតែមានសភាពលក្ខណៈងាយស្រួលនិងលក្ខណៈលំបាក កប់នៅលាយឡំជាមួយគ្នាជាធម្មតា។ ទុកជាមានសភាពលក្ខណៈដូច្នេះក៏ដោយ ភាសានីមួយៗ តែងតែមានក្បួនច្បាប់របស់ខ្លួនទៅតាមសម័យកាល។ ការខិតខំតម្រឹមតម្រង់គន្លងភាសាឲ្យបានត្រឹមត្រូវ មានឯកភាពនៅក្នុងរង្វង់ក្បួនច្បាប់សុទ្ធ សមតាមបែបបទវិទ្យាសាស្ត្រពេញទី ចាត់ទុកជាការពិបាកមួយដែលអាចបណ្ដាលមកអំពីការវិវត្តន៍នៃសង្គមមនុស្ស តម្រូវមនុស្សឲ្យដើរលឿនមុខក្បួនច្បាប់ ឬដើរងាកចេញពីក្បួនច្បាប់ ដើម្បីប្រយោជន៍សេដ្ឋកិច្ចជាតិនិងឯកភាពជាតិ ឬក៏មកអំពីការមិនចុះសម្រុងគ្នារវាងបែបចាស់និងបែបថ្មី ឬមួយមកអំពីដំណើរច្របល់នៃវប្បធម៌ដែលមិនច្បាស់លាស់ថាជារបស់ខ្លួនឬរបស់គេ។ ភាសាខ្មែរសម័យខេមរយានកម្ម បានប៉ះទង្គិចនឹងឧបសគ្គបែបនេះខ្លះដែរ តែការប៉ះទង្គិចនេះ

បានរលាយខ្សុលទៅវិញ ដោយសារតែ **ខេមរយានកម្មជាអង្គការជាតិនិយម** ផ្ដល់អាទិភាពធំទូលំទូលាយក្នុងការបកប្រែពាក្យបច្ចេកទេសបរទេស ជាពាក្យពេចន៍ខ្មែរសុទ្ធៗ មុខនឹងបែរទៅរកពាក្យបាលីសំស្រ្កឹត បារាំង អង់គ្លេស ពីព្រោះតែយល់ថា ត្រូវញុំាងវិវត្តន៍ភាសាខ្មែរឲ្យស្របទៅតាមគោលច្បាប់ខ្មែរបុរាណ។

ដោយការក្ដាប់យកគំនិតនេះជាគោល ខេមរយានកម្មសិក្សា *គ្មានផលប្រយោជន៍អ្វីទៅបង្កើតការពិបាកថ្មីទៅលើការពិបាកចាស់នោះឡើយ* ។ មិនយូរមិនឆាប់ខេមរយានកម្មនឹងប្រែក្លាយទៅជាភ្នាក់ងារចម្បងមួយ ក្នុងការដោលភាសាជាតិឲ្យលឿនទៅមុខ ទាន់ការចាំបាច់នៃសង្គមខ្មែរ សម័យសង្គមរាស្ត្រនិយមពុទ្ធសាសនា សម័យសម្ដេចព្រះសីហនុ។

អាត្មាមានជំនឿស៊ប់លើអង្គការខេមរយានកម្មនេះហើយ ពេញអធ្យាស្រ័យចូលរួមសហប្រតិបត្តិការជាមួយ ដោយគ្មានគិតដល់ការបង់ខាតពេលវេលា និងនឿយកាយពលសោះឡើយ។

ភ្នំពេញ, ថ្ងៃទី៩ កញ្ញា ១៩៦៨

សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ **ជួន – ណាត** ជោតញ្ញាណោ



ព្រះរាជសុន្ទរកថានៃសម្តេចព្រះប្រមុខរដ្ឋ
ក្នុងឱកាសថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ
**ចំពោះសម្តេចព្រះសង្ឃរាជ**
**ជួន - ណាត**

សម្តេចជាអម្ចាស់ ជាទីសក្ការៈ
ព្រះថេរានុត្ថេរៈ ជាទីគោរព,
ឯកឧត្តម, អស់លោក,
ជនរួមជាតិជាទីស្នេហា!

ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ មានបីតិសោមនស្សណាស់ ដោយបាន មកជាអធិបតីក្នុងពិធីដ៏មហោឡារិកនេះ។ មានសេចក្ដីរីករាយជាខ្លាំង ចំពោះ ភូមិន្ទសកលវិទ្យាល័យយើង ដែលបានសម្រេចលើកតម្កល់ព្រះអង្គសម្ដេចព្រះ សង្ឃរាជ ក្នុងឋានៈអ្នកប្រាជ្ញទី១ របស់យើងផ្នែកខាងអក្សរសាស្ត្រខ្មែរ។ ទូល បង្គំខ្ញុំព្រះករុណា ខ្ញុំសូមសរសើរ ហើយថ្លែងអំណរគុណលោក សកលវិទ្យាធិការ លោកមហាវិទ្យាធិការ និងសាស្ត្រាចារ្យទាំងអស់ ដែលបាន សម្រេចថ្វាយព្រះកិត្តិយស និងគារវភក្តិ ចំពោះសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ដែលព្រះអង្គមានព្រះកិត្តិនាមល្បីល្បាញតាំងពីយូរមកហើយ គឺសម្ដេចព្រះ សង្ឃរាជព្រះអង្គមាននាទីផ្ដាច់គេ ក្នុងវិស័យចំណេះវិជ្ជានិងស្នាព្រះហស្ត គឺ ដោយសារសម្ដេចនេះហើយ ទើបអក្សរសាស្ត្រយើងមានទម្រង់ទាន់សម័យ។ ព្រះអង្គទ្រង់បានកំណត់ក្បួនវេយ្យាករណ៍ខ្មែរ ឲ្យត្រឹមត្រូវ ទាំងខាងវាក្យសម្ពន្ធ ក៏ដូចជាខាងការអានឲ្យច្បាស់លាស់។ ហើយចំណែកខាងស្នាព្រះហស្ត ព្រះ អង្គផ្នែកគរុកោសល្យ និង អក្សរសាស្ត្រក៏មានសារៈប្រយោជន៍លេខ ១ គឺព្រះ អង្គសម្ដេចព្រះសង្ឃរាជនេះហើយ ដែលជាឫសគល់នៃវឌ្ឍនភាពរបស់ខ្មែរ ដែលឥឡូវសម្បូណ៌ដោយពាក្យពេចន៍ប្រើប្រាស់ ប្រកបទៅតាមការចាំបាច់នៃ សម័យថ្មី។ សម្ដេចព្រះអង្គបានជួយស្រោចស្រង់ភាសាខ្មែរយើង ឲ្យជៀសវាង នូវការគាំងដំណើរ របស់ភាសាបុរាណជាច្រើន។ ដូច្នេះព្រះឋានៈជាមហា បណ្ឌិតខាងអក្សរសាស្ត្រ ដែលបានប្រគល់ថ្វាយក្នុងពេលនេះ គឺជាសក្ខីភាព នៃកតញ្ញូតាធម៌ចំពោះព្រះអង្គ ក្នុងវិស័យពហុវិជ្ជា គឺព្រះអង្គមានចំពោះជាតិ មាតុភូមិ នូវមហាគុណូបការៈដែលគ្មាននរណាប្រកែកើត។

អក្សរសាស្ត្រខ្មែរ ផ្នែកទូទៅហើយនិងផ្នែកសាសនាផុសឡើងវិញហើយ អំពីរាត្រីកាលដ៏អាប់អួរមួយដ៏យូរលង់។ ការលួចប្លន់និងដុតបំផ្លាញ រាជធានី អង្គរដែលសៀមបានធ្វើ ជាហេតុមួយបណ្ដាលឲ្យខ្មែរបានពើបប្រទះនូវ មហន្តរាយ ដែលមានទំហំធំលើសមហន្តរាយនៃអារ្យប្រទេសជាតិដទៃក្នុង

ប្រវត្តិសាស្ត្រ។ កងទ័ពឈ្លានពានវាបានរាតត្បាតព័ទ្ធព័ន្ធប្រទេសខ្មែរស៊ីវិល័យ ហើយវាបានបំផ្លាញគ្រប់បែបយ៉ាង នូវសៀវភៅនិងក្បួនខ្នាតដែលបុព្វបុរសយើង បានតាក់តែងយ៉ាងអំណត់ មកតាំងពីច្រើនសតវត្សហើយ។ ឯកសារទាំងនោះ គឺជាឃ្លាំងនៃប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ និងវិទ្យាសាស្ត្រ។ ពួកប្លន់ទឹកដីខ្មែរក្នុងសម័យនោះ វាជាអនក្ខរជន វាច្រណែនយ៉ាងខ្លាំង ចំពោះជាតិសាសន៍ខ្មែរ វាខឹងសម្បារនឹងការលូតលាត់ចម្រើននៃអារ្យធម៌ខ្មែរយើង។

ប្រាកដណាស់ សៀមដណ្តើមប្លន់យកអស់ទាំងអ្វីដែលជាតម្លៃរបស់ជាតិយើង វាចម្លងលក្ខណៈអក្សរយើង វាផ្ចិតយកបែបរដ្ឋបាលសម័យអង្គរយើង ហើយវាបំប្លែងនូវសំណល់រឿងឯកសារនៃអក្សរសាស្ត្រយើង ដែលមិនឆេះរលាយ ឲ្យទៅជារបស់វា។ ស្របជាមួយនឹងការណ៍នេះ ហើយរហូតមកដល់សតវត្សទី ១៧ សៀមបានដុតបំផ្លាញនូវបណ្ណាល័យ ដែលបានរៀបចំវិញខ្លះក្នុងសម័យលង្វែកទល់នឹងសម័យឧដុង្គ។ សៀមវាមានបំណងផ្តាច់ខ្មែរ អំពីអតីតកាលដ៏ថ្កើងរុងរឿងនៃខ្លួន។ យើងអាចរក្សាទុកបាននូវអារ្យធម៌ខ្មែរ ក្នុងសម័យដើមនោះ ដោយសារតែសិលាចារឹកនៅលើផែនថ្ម ហើយនិងការចេះចម្លងក្បួនតម្រា-តៗគ្នាដោយមាត់ទទេ។

**បន្តពីសៀមមក** ពួក **យួន** បានខិតខំធ្វើបាបខ្មែរ វាពុំអាចបញ្ចូលបាននូវវប្បធម៌របស់វាមកក្នុងប្រទេសយើងឡើយ។ រហូតមកដល់សតវត្សទី ១៩ រាជបល្ល័ង្កដែលជាអង្គការការពារហើយលើកទឹកចិត្តជួយសិល្បៈ និងអក្សរសាស្ត្រ ទស្សនវិជ្ជា និងសាសនាជានិច្ចរៀងមក ត្រូវពើបប្រទះនូវអភ័ព្វគ្រប់បែបយ៉ាង ដែលធ្វើឲ្យអស់នូវលទ្ធភាពឧបត្ថម្ភវប្បធម៌ជាតិ ដោយខ្លួនរវល់តែផ្លាស់កន្លែងពីនេះទៅនោះ ក្នុងគ្រាដ៏លំបាកនោះខ្មែរយើងខ្វះនូវអ្នកកត់ត្រាប្រវត្តិសាស្ត្រករឺអ្នកនិពន្ធ ដើម្បីសរសេរទុកឲ្យបានគង់វង្សនូវរឿងរ៉ាវ ឬនូវចម្រៀងដែលបង្ហាញអំពីវីរភាពរបស់ខ្មែរក្នុងសម័យរងទុក្ខវេទនា។ រីឯពុទ្ធសាសនាយើង ក៏ត្រូវចុះអន់ថយ ហើយមានវិវត្តន៍ទៅតាមជំនឿឆ្វេង ជំនឿ

ក្រៅសាសនា ដែលផ្ទុយអំពីទ្រឹស្តីបរិសុទ្ធនៃព្រះបរមគ្រូ។ ការប៉ុនប៉ងរៀបចំទម្រង់ថ្មីឡើងវិញ ចាប់ផ្តើមនៅក្នុងរជ្ជកាលនៃ ព្រះករុណាព្រះបាទសម្តេចព្រះហរិក្សរាមាធិបតី ព្រះ**អង្គឌួង** ។ ប៉ុន្តែចម្បាំងថ្មីទៀតជាមួយសៀម និងយួននាំឲ្យរំខានដល់ការខិតខំផ្តួចផ្តើមនេះ។

អាណាព្យាបាលបារាំងសែស បាននាំមកឲ្យយើងនូវសន្តិភាពនិងស្ថិរភាពខ្លះដែរ។ ប៉ុន្តែពួកអាណាព្យាបាលនេះ គេគ្មានផលប្រយោជន៍អ្វីនឹងរៀបចំនូវវប្បធម៌ជាតិរបស់យើងឡើយ។ ជាកុសល សម័យនោះមានអ្នកស្នេហាជាតិយើងមួយក្រុម ចេះរួបរួមគ្នាសម្រេចចិត្តពញ្ញាក់ស្មារតីជាតិឲ្យភ្ញាក់រលឹក គិតទៅដល់ការចុះអន់ថយនៃអក្សរសាស្ត្រនិងដល់តម្លៃនៃសាសនាយើង។ ក្នុងចំណោមវរជនទាំងនោះមានព្រះរាជអយ្យកោខាងបិតារបស់ ទូលព្រះបង្គំ-ខ្ញុំគឺ សម្តេចវរចក្ររណរិទ្ធិ **សុទ្ធារស** ដែលព្រះអង្គត្រូវអាក់ខានបានសោយរាជសម្បត្តិ ព្រោះតែអាណានិគមនិយមបារាំងមិនសប្បាយចិត្តនឹងសកម្មភាពព្រះអង្គ ដែលជាអ្នកការពារឧត្តមប្រយោជន៍និងកិត្តិយសជាតិ។

ក្នុងសម័យនោះសម្តេច **ជួន ណាត** និងសម្តេច **ហួត តាត** ព្រះអង្គមានយុវភាពនៅឡើយ។ ប៉ុន្តែព្រះអង្គមានសមត្ថភាពពេញទី ដើរជួរមុខនៃចលនាស្រោចស្រង់និងលើកតម្លៃវប្បធម៌ជាតិ ដើម្បីបើកនិងត្រាយផ្លូវនៃការលូតលាស់ចម្រើនដ៏ពិតប្រាកដនៃបុនភាព (renaissance) របស់វប្បធម៌ខ្មែរ ដែលបន្តដំណើរជានិច្ច មកទល់សព្វថ្ងៃនេះ មុខការដែលត្រូវបំពេញមានទំហំធំធេងណាស់។ បណ្ឌិតសន្និបាតមួយប្រកបដោយអ្នកប្រាជ្ញមានសទ្ធាជ្រះថ្លាដ៏ឧត្តមមានចិត្តក្លាហាន ធ្វើការយ៉ាងសកម្ម ហើយមានរបៀបបែបផែនវិទ្យាសាស្ត្រនិងបច្ចេកទេសផង បានពុះពារនឹងមុខការនេះ។

ព្រះអង្គខ្លះដូចជាព្រះអយ្យកោទូលព្រះបង្គំ ខ្ញុំ សម្តេច **លី ឯម** និងអ្នកប្រាជ្ញច្រើនទៀតបានអនិច្ចកម្មនៅកំពុងបំពេញសកម្មភាព។ សព្វថ្ងៃនេះ

ក្រុមអ្នកប្រាជ្ញជំនាន់នោះ ពិសេសគឺសម្ដេច **ជួន ណាត** និង **ហួត តាត** ព្រះអង្គនៅតែបន្តការងារនេះគ្មានងាករេ ព្រះអង្គយាងត្រង់តាមមាគ៌ាដែលបានដៅទុកមក។

វឌ្ឍនភាព យ៉ាងធំមួយបានសម្រេចហើយ ក្នុងការសំរឹតសំរាំងពាក្យដែលត្រូវខ្ចី ឬ ត្រូវប្រែមកពីបរទេសហើយក្នុងការសម្ដែងស្វែងរកឲ្យបានត្រឹមត្រូវតាមព្រះធម៌ និងព្រះវិន័យរបស់ព្រះពុទ្ធជាម្ចាស់។ ក្នុងករណីនេះ គួរសរសើរចំពោះការបកប្រែ ការបោះពុម្ពនិងការផ្សាយព្រះត្រៃបិដកដែលមានជំនឿជឿនលឿនទៅមុខ យ៉ាងទៀងទាត់ឥតខ្ចោះ។ អ្នកខ្លះនិយាយខុសទាំងស្រុងថា នៅក្នុងសាសនាយើងមានធម៌ថ្មី - ធម៌ចាស់។ តាមការពិតយើងពុំមានធម៌ ២ ទេ។ មានតែមួយគត់។ ដែលនិយាយថាជាធម៌ថ្មីនោះ គឺជាការដែលខំសំរឹតសំរាំងព្រះសាសនា ឲ្យផុតពីជំនឿខុស អំពីការយល់ហួសហេតុផល និងទម្លាប់ខុស គឺពុំមែនធ្វើឲ្យពុទ្ធសាសនាទៅជាបែបថ្មីទេ។ ការពិត គឺធ្វើឲ្យព្រះសានសត្រឡប់ទៅរកប្រភពដើម ដ៏ត្រឹមត្រូវល្អវិញតែប៉ុណ្ណោះ។

----------

ជាមួយនឹងឯករាជ្យជាតិ ភាសាជាតិត្រូវមាននាទីដ៏ធំ ហើយបំពេញមុខងារដ៏ខ្ពង់ខ្ពស់។ ខ្មែរយើងក៏បានរៀបចំភាសាជាតិ ឲ្យនៅជាឧបករណ៍សម្រាប់ប្រើឲ្យសមទៅតាមការចាំបាច់នៃឯករាជ្យជាតិ។ សម្ដេចជាអម្ចាស់ព្រះអង្គបានដឹកនាំប្រជាជាតិ ក្នុងការប្រើពាក្យនិមួយៗឲ្យចំន័យល្អត្រឹមត្រូវ។ ព្រះអង្គព្រះរាជបណ្ឌឲ្យចៀសវាងនូវការច្រឡំ ក្នុងការជ្រើសរើសពាក្យ ហើយនិងការប្រើពាក្យផ្ទុយខុសអំពីគំនិត។ ព្រះអង្គបានដឹកនាំឲ្យបំពេញនូវការកំណត់ក្បួនវេយ្យាករណ៍ និងវាក្យសម្ព័ន្ធនូវការបង្កើតពាក្យ ដើម្បីប្រើប្រាស់ក្នុងវិទ្យាសាស្ត្របច្ចេកទេស នយោបាយនិងអក្សរសាស្ត្រ។ សម្ដេចព្រះសង្ឃរាជ ទ្រង់គង់នៅជាប្រមុខនៃចលនារៀបចំបែបថ្មី ឲ្យស្រុបតាមកាលសម័យនៃវប្បធម៌ រីក

ចម្រើននេះ។ ទូលព្រះបង្គំ ខ្ញុំសូមបន្ថែមថា ទោះបីព្រះអង្គមានវ័យចាស់ក៏ដោយ ក៏សម្ដេចព្រះសង្ឃរាជ ទ្រង់នៅមានសកម្មភាពណាស់។ ទ្រង់បានបង្កើតសមិទ្ធិច្រើនអនេកប្បការ គឺព្រះអង្គនៅមានភាពជាយុវវ័យនៅឡើយ។ ដ៏ពិតណាស់ វរជន-អ្នកប្រាជ្ញក្មេងៗ ក៏ពុំអាចមានថាមភាពនិងប្រសិទ្ធិភាពស្មើនឹងព្រះអង្គបានឡើយ។ នៅក្នុងពុទ្ធិកវិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យ នៅក្នុងគណៈកម្មការនានា និងអង្គការផ្សេងៗ ខាងអក្សរសាស្ត្រ សម្ដេចព្រះសង្ឃរាជ ទ្រង់ជាសាស្ដា និងជាអ្នកចាត់ចែងដឹកនាំឧបត្ថម្ភជានិច្ច។ ជាងនេះទៅទៀត ការងារដ៏ធ្ងន់ក្រៃលែងនេះ ពុំមែនតម្កល់ព្រះអង្គត្រឹមតែជាអ្នកនិពន្ធពហុផលប៉ុណ្ណោះទេ ពិសេសព្រះអង្គជាកវី ដែលក្រៅអំពីស្នាព្រះហស្ដទាំងឡាយ គឺមានពាក្យពេចន៍បទចំរៀង «**នគររាជ**» ដែលទ្រង់និពន្ធនៅដើមរាជ្យរបស់ទូលព្រះបង្គំខ្ញុំ គឺក្នុងឆ្នាំ ១៩៤១។

អក្សរសាស្ត្រខ្មែរយើងផ្នែកសាសនា, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ, និរុត្តិសាស្ត្រជាបាលីនិងសំស្ក្រឹតមានតម្លៃ មានឋានៈដ៏ខ្ពង់ខ្ពស់ឧដុង្គឧត្ដមណាស់ទៅលើផ្ទៃរាបអន្តរជាតិ និងក្នុងចំណោមនៃអត្ថបទនានាដ៏មានតម្លៃនៃវប្បធម៌សកលលោក។ ប៉ុន្តែយើងមានសេចក្ដីស្ដាយចំពោះសភាពទន់ខ្សោយនៃអក្សរសាស្ត្រផ្នែក រឿងរ៉ាវធម្មតាដូចជាប្រលោមលោក នវកថា ។ល។ . . . បុព្វហេតុនៃសភាពទន់ខ្សោយនេះ គឺបណ្ដាលមកតែអំពីសម្ដេចនិងព្រះភិក្ខុសង្ឃជាអ្នកចេះដឹង យើងព្រះអង្គពុំអាចចូលរួមបានក្នុងចលនាបែបនេះ ពីព្រោះផ្ទុយនឹងវិន័យរបស់ព្រះអង្គ។

អ្នកទទួលខុសត្រូវក្នុងវិស័យអក្សរសាស្ត្រ បែបធម្មតាច្រើនតែឈ្លក់ទៅក្នុងនយោបាយ មនោគមវិជ្ជាឬមួយជាអ្នកគិតតែពីរឿងរកចំណេញលុយ ដែលជាហេតុដឹកនាំគេឲ្យធ្លាក់ទៅក្នុងផ្លូវផ្ទុកនឹងសីលវិជ្ជា ឬមួយផ្លូវទាបថោក។ ចំណែកជនរួមជាតិយើង ដែលមានគំនរវិជ្ជាអន្តរជាតិឬមួយមិនប្រសប់ប្រើនូវភាសាជាតិដោយពុំយល់ជ្រៅជ្រះ ឬមួយជាប់រវល់នឹងមុខងារខាងនយោបាយ

ឬក្នុងមុខក្រសួងរាជការវិញ ក៏ជាឧបសគ្គឃាំងពុំឲ្យគេចូលមកជួយលើកតម្កើងអក្សរសាស្រ្តជាតិរបស់ខ្លួនបាន។ តែក្នុងខណៈនេះស្នាព្រះហស្តដ៏ល្អលើសលុបនិងមិនចេះសាបសូន្យនៃសម្តេចព្រះសង្ឃរាជ **ជួន ណាត** តែមួយព្រះអង្គនេះ ក៏គ្រប់គ្រាន់បរិបូណ៌និងបញ្ចាំងនូវរស្មីចិញ្ចែងនៃអក្សរសាស្រ្តរបស់ប្រទេសជាតិយើងទាំងមូលទៅលើឆាកអន្តរជាតិ។ គឺជាភ័ព្វសំណាងធំអស្ចារ្យរបស់យើង ដែលមានព្រះអង្គសម្តេចជាបុត្រនៃកម្ពុជរដ្ឋ។ រួចមកហើយព្រះអង្គសម្តេច ព្រះអង្គជា **«ព្រះរាជា»** នៃព្រះសាសនាដ៏វិសិដ្ឋរបស់យើង, ហើយពិសេសទៅទៀត ប្រវត្តិសាស្រ្តច្បាស់ជាទទួលកត់ត្រាទុកព្រះអង្គជា **ព្រះរាជានៃអក្សរសាស្រ្តខ្មែរ** ជាប្រាកដ។



សម្តេចនិងភិក្ខុសង្ឃសៀម ដោយមានព្រះឃោសធម្ម
ប៉ុណ្ណ-សម្ភាជ អមផង។

## សុន្ទរកថានៃសហជីវិនសាកលវិទ្យាធិការ

សាកលវិទ្យាល័យភូមិន្ទ ថ្លែងក្នុងពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ
ចំពោះសម្តេចព្រះសង្ឃរាជ

សូមព្រះតេជតំកល់លើត្បូង
សូមព្រះរាជទានក្រាបបង្គំទូលសម្តេចឪ
សូមព្រះរាជទាន ក្រាបបង្គំទូលសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ
សូមក្រាបបង្គំទូលសម្តេចព្រះសង្ឃនាយក សូមទ្រង់ជ្រាប។
សូមក្រាបបង្គំទូលសម្តេចព្រះពោធិវង្ស
សូមក្រាបថ្វាយបង្គំចំពោះ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ
សូមជម្រាបឯកឧត្តម អស់លោក លោកស្រីទាំងឡាយ
សូមទានជ្រាប សូមជ្រាប។

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស គួរកត់ទុកក្នុងប្រវត្តិសាស្ត្រនៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដោយសម្តេចឪជាព្រះបិតាអប់រំជាតិ ទ្រង់ស្តេចយាងមកជាព្រះអធិបតីក្នុងពិធីថ្វាយ «សញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ» ចំពោះសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជជោតញ្ញាណោ **ជួន ណាត**។

ជាបឋម ទូលព្រះបង្គំ សូមថ្លែងនូវអំណរដ៏ខ្ពង់ខ្ពស់ ចំពោះព្រះករុណាទិគុណដ៏ថ្លៃវិសេសនៃសម្តេចឪ ដែលព្រះអង្គទ្រង់ព្រះមេត្តាប្រោសយាងមកជាកិត្តិយស ដើម្បីញ៉ាំងពិធីនេះឲ្យបានរុងរឿងយ៉ាងឱឡារិកក្រៃលែង។

**បពិតសម្តេចឪ**

ប្រទេសកម្ពុជា មានជោគវាសនាយ៉ាងក្រៃលែង ដោយបានព្រះអង្គជាព្រះអគ្គមគ្គុទេសក៏ដ៏ឆ្នើម របស់ប្រជាជាតិខ្មែរ ព្រះអង្គបានកសាងឯករាជ្យ

ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយម ដែលជាចលនាបង្រួបបង្រួមជាតិ។ ឯមាគ៌ានយោបាយសង្គមបានចែងជាក់ច្បាស់ ពីការស្ថាបនាប្រទេសតាមបែបលក្ខណៈជាតិនិយម ពោលគឺកសាងគ្រប់វិស័យដោយធ្វើយ៉ាងណាឲ្យមានវឌ្ឍនភាព ដើម្បីលើកស្ទួយនយោបាយ សេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ឲ្យមានស្ថិរភាពដូចអារ្យប្រទេសនានា។

តាំងពីសម័យសង្គមរាស្ត្រនិយមកើតមក វប្បធម៌និងអារ្យធម៌ បានរីកចម្រើនជាអតិបរមា ការលូតលាស់ដ៏ខ្ពស់ខ្ពស់នេះ បានស្ថិតជាប់នឹងខ្សែមាគ៌ាវប្បធម៌ខ្មែរ ដោយមានក្បួនខ្នាតទ្រឹស្តី នៃអារ្យធម៌សម័យអង្គរល្បីល្បាញរុងរឿងជាគោលអនុវត្តន៍។ មិនត្រឹមតែរក្សាទុកនូវគោលលក្ខណៈជាតិប៉ុណ្ណោះទេ ការស្ថាបនាទាំងឡាយតែងគោរពពេញលក្ខណៈ តាមគោលមាគ៌ាសង្គមរាស្ត្រនិយម បែបសង្គមរាស្ត្រនិយមព្រះពុទ្ធសាសនា។ គួរយ៉ាងដូចជាពិធីថ្វាយសញ្ញាប័ត្រ ចំពោះសម្តេចព្រះសង្ឃរាជក្នុងគ្រានេះ ជាពិធីដ៏មហោឡារិកយ៉ាងក្រៃលែង បង្ហាញនូវសក្ខីភាព ជានិមិត្តរូប នៃការលូតលាស់ផ្នែកអក្សរសាស្ត្រក្នុងសម័យសង្គមរាស្ត្រនិយម។

សញ្ញាប័ត្រដែលសកលវិទ្យាល័យភូមិន្ទ ចាត់ចែងថ្វាយសម្តេចព្រះសង្ឃរាជក្នុងពេលនេះ មិនមែនជាសញ្ញាប័ត្រកិត្តិយសឬសញ្ញាប័ត្រពិសេសទេ គឺជាសញ្ញាប័ត្រពេញលក្ខណៈ ដែលជាលទ្ធផលនៃការពិនិត្យតាមនីតិវិធី ដ៏ត្រឹមត្រូវរបស់គណៈកម្មការ ដែលតែងតាំងក្នុងក្របខណ្ឌនៃច្បាប់ជាធរមាន។

របៀបពិនិត្យស្នាដៃ ដើម្បីឋានៈបណ្ឌិតខាងអក្សរសាស្ត្រនេះមាន ២ យ៉ាងគឺ៖

-របៀបទី១ ដែលគេនិយមប្រើនៅប្រទេសបារាំងជាដើមគឺគណៈកម្មការពិនិត្យនិក្ខេបបទ របស់បេក្ខជនហើយធ្វើសំណួរជាសាធារណៈ។

-របៀបទី២ ដែលគេធ្លាប់ប្រើនៅប្រទេសខ្លះ គណៈកម្មការពិនិត្យស្នាដៃទាំងឡាយនៃបេក្ខជន តាមលក្ខណៈច្បាប់។

គណៈកម្មការដែលពិនិត្យស្នាព្រះហស្ត នៃសម្ដេចព្រះសង្ឃរាជ តែងតាំងតាមរបៀបទី ២ ខាងលើនេះ គឺដោយគោរពតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់ នៃសម្ដេចព្រះប្រមុខរដ្ឋ សហជីវិនសកលវិទ្យាធិការ ក៏ជ្រើសតាំងគណៈកម្មការមួយ។

គណៈកម្មការនេះ ក្រោយដែលបានពិនិត្យស្នាព្រះហស្តនៃសម្ដេចព្រះសង្ឃរាជ បានប្រជុំនៅថ្ងៃទី ៧ មេសា ១៩៦៧ ហើយបានសម្រេចថា ព្រះអង្គសមនឹងទទួលសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រមែន។

ឯស្នាព្រះហស្តដែលគណៈកម្មការបានពិនិត្យ មានជាអាទិ៍គឺវចនានុក្រមទាំងពីរភាគ។

ប្រវត្តិនៃវចនានុក្រមនេះ មានព្រះរាជប្រកាសលេខ ៦៧ ចុះថ្ងៃទី ៤ ធ្នូ ១៩១៥ តែងតាំងឲ្យមានក្រុមជំនុំមួយសម្រាប់តែងវចនានុក្រមខ្មែរនេះ។ ក្នុងក្រុមជំនុំនេះសម្ដេចព្រះសង្ឃរាជបានបំពេញមុខងារជាលេខាធិការ តាំងពីឆ្នាំ ១៩១៥ ដល់ ១៩១៩។

ក្នុងឆ្នាំ ១៩១៩ នោះ ព្រះអង្គត្រូវបានតែងតាំងជាសមាជិកពេញទី។ លំដាប់តមកនៅឆ្នាំ ១៩២៧ ព្រះអង្គបានទទួលភារៈធ្វើវចនានុក្រមតែមួយព្រះអង្គឯង ដរាបបានចប់សព្វគ្រប់ហើយ បានបោះពុម្ពផ្សាយ ទាំងភាគមួយទាំងភាគពីរ។ ដូច្នេះតាមការពិត វចនានុក្រមខ្មែរដែលយើងប្រើសព្វថ្ងៃនេះ ជាស្នាព្រះហស្តសម្ដេចព្រះសង្ឃរាជ។

វចនានុក្រមនេះ ជាស្នាព្រះហស្តពិសេស ដែលជនជាតិខ្មែរទូទាំងប្រទេសទទួលស្គាល់តម្លៃគ្រប់ៗគ្នា ហើយប្រើជាគោលនៃភាសាខ្មែរសព្វថ្ងៃនេះ។ តាំងពីវចនានុក្រមនេះប្រសូតមក ភាសាខ្មែរមានលក្ខណៈវិនិច្ឆ័យ ដ៏ពិតប្រាកដ។ សៀវភៅនេះជាគោលច្បាប់ដ៏សំខាន់សម្រាប់អក្សរសាស្ត្រខ្មែរ ប្រៀបបានទៅនឹងក្រមបវេណី សម្រាប់ច្បាប់បវេណី។ ចៅក្រមដែលវិនិច្ឆ័យរឿងបវេណី តែងយោងទៅតាមបវេណីយ៉ាងណា អ្នកសរសេរភាសាខ្មែរក៏តែង

យោងទៅវចនានុក្រមយ៉ាងនោះដែរ។

វចនានុក្រមនេះ មានប្រយោជន៍មួយទៀតខាងនយោបាយអក្សរសាស្ត្រ គឺធ្វើឲ្យភាសាជាតិផុតអំពីវិបត្តិផ្សេងៗ ផុតអំពីអនាធិបតេយ្យខាងភាសា ផុតអំពីការប្រទ្បូកប្រទ្បំខាងអក្ខរាវិរុទ្ធ ពោលគឺធ្វើឲ្យភាសាជាតិមានឯកភាពខាងពាក្យពេចន៍។

ក្រៅអំពីវចនានុក្រមខ្មែរ ព្រះអង្គបាននិពន្ធកច្ចាយនូបត្ថម្ភកៈ ដែលមានពីរភាគ គឺជាសៀវភៅខាងវេយ្យាករណ៍បាលី ព្រះអង្គបាននិពន្ធទំនុកបទនគររាជ និងទំនុកបទសរភញ្ញ។ ស្នាព្រះហស្តរបស់ព្រះអង្គមានចំនួនជាង ២០ ទៀត ដែលច្រើនទាក់ទងទៅនឹងសាសនាហើយដែលទូលព្រះបង្គំ ជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមមិនលើកមករៀបរាប់ក្នុងទីនេះទេ ព្រោះពុទ្ធបរិស័ទតែងស្គាល់នូវសៀវភៅទាំងនោះអស់ហើយ។

ក្រៅពីស្នាព្រះហស្តខាងលើនេះ ព្រះរាជសម្ភាសន៍ដែលព្រះអង្គព្រះរាជទានរាល់ថ្ងៃពុធ ហើយដែលវិទ្យុជាតិផ្សាយរាល់ថ្ងៃសុក្រ សន្មតថាជាសមិទ្ធិនៃសង្គមដ៏សំខាន់។

ព្រះរាជសម្ភាសន៍នេះ អាចចាត់ជាថ្នាក់បង្រៀនជាសាធារណៈមួយដែលខ្មែរអ្នកស្រលាញ់អក្សរសាស្ត្រក្រេបជញ្ជក់យករសជាតិបានគ្រប់ៗរូប។

ព្រះសមត្ថភាពរបស់សម្ដេចព្រះសង្ឃរាជ មិនមានត្រឹមតែក្នុងអក្សរសាស្ត្រជាតិប៉ុណ្ណោះទេ ព្រះអង្គថែមទាំងចេះភាសាបាលី ចេះភាសាបរទេស អាចអានឬសន្ទនាតាមសំនៀងបរទេសនោះបានផង គឺសំនៀងលង្កា ភូមា មន សៀម លាវ។ ព្រះអង្គចេះភាសាបារាំងដោយមានសំនៀងគួរសរសើរ ភាសាអង់គ្លេស និងភាសាវៀតណាមខ្លះ។ ព្រះអង្គបានបំពេញវិជ្ជា ខាងភាសាសំស្ក្រឹត និងអក្សរសិលាចារឹកនៅក្នុងហាណូយ។

ម្យ៉ាងទៀតព្រះរាជកិត្តិសព្ទរបស់ព្រះអង្គ បានឆ្លងចេញផុតពីព្រំដែនកម្ពុជា ហើយល្បីល្បាញដល់បរទេសទៀត ភស្តុតាងគឺនៅឆ្នាំ ១៩៤៣ ព្រះ

អង្គបានទទួលនាទីជាសមាជិកឆ្លើយឆ្លងនៃសាលាបារាំង នៅចុងបូព៌ាប្រទេស (Ecole française d'Extrème Orient) នៅឆ្នាំ ១៩៤៨ ព្រះអង្គបានឡើងព្រះឋានៈជាសមាជិកកិត្តិយសនៃសាលានេះជាដរាបដល់សព្វថ្ងៃ។

ចំណែកឯប្រទេសភូមាវិញ បានថ្វាយព្រះឋានៈព្រះអង្គជាអគ្គមហាបណ្ឌិតនៅឆ្នាំ ១៩៥៤ និង ឋានៈជាអតិធជមហារដ្ឋគុរុសហភាពភូមា គឺថា គ្រូដ៏ធំរបស់រដ្ឋ ដូចទង់មហាប្រសើរ នៅឆ្នាំ ១៩៥៧។

សម្តេចព្រះសង្ឃរាជ ព្រះអង្គពុំមែនគ្រាន់តែមានព្រះសកម្មភាពកសាងវប្បធម៌ អក្សរសាស្ត្រជាតិតែប៉ុណ្ណោះទេ ព្រះអង្គថែមទាំងជួយឧបត្ថម្ភចំពោះចលនាសង្គមរាស្ត្រនិយមនេះយ៉ាងក្រៃលែងទៀត គឺព្រះអង្គទ្រង់បានជួយជាព្រះវិភាគទាន ក្នុងការកសាងជាតិ ដូចជាកសាងវត្តអារាម ស្ថាបនាព្រះវិហារមន្ទីរពេទ្យ សាលាពុទ្ធិកបឋមសិក្សាជាដើម ហើយព្រះអង្គទ្រង់ព្រះរាជទានព្រះឱវាទដល់ព្រះសង្ឃក្នុងព្រះរាជាណាចក្រ ឲ្យជួយឧបត្ថម្ភដល់ការកសាងជាតិតាមលក្ខណៈលទ្ធិសង្គមនិយមបែបពុទ្ធសាសនា មានការស្ថាបនាផ្លូវថ្នល់សាលារៀន ។ល។

បពិត្រសម្តេចព្រះសង្ឃរាជជាទីគោរព

ព្រះសកម្មភាពរបស់ព្រះអង្គខាងអក្សរសាស្ត្រជាតិនេះ បរិបូណ៌ក្រៃលែងណាស់។ ព្រះសមត្ថភាពនេះ លើសពីឋានៈបណ្ឌិតខាងអក្សរសាស្ត្រដែលសាកលវិទ្យាល័យភូមិន្ទថ្វាយព្រះអង្គក្នុងពេលនេះទៅទៀត។ ប៉ុន្តែដោយហេតុគ្មានរបស់អ្វីជាឧត្តម សមគួរ ប្រសើរលើសនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសទទួលនូវសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រនេះ ដែលជាសក្ខីភាពដ៏ស្ងួចស្ដើងនៃកតញ្ញូតានិងសេចក្តីគោរព សក្ការៈរបស់ក្រសួងសិក្សាធិការជាតិ ដែលសម្តេចព្រះប្រមុខរដ្ឋនឹងថ្វាយចំពោះព្រះអង្គក្នុងពេលបន្តិចទៀតនេះ។ (ថ្ងៃ២៨ ឧសភា ១៩៦៧)

# កាព្យរំលឹកអំពីអក្សរខ្មែរ

ព្រះរាជនិពន្ធសម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ

**បទពាក្យ ៧**

## អក្សរខ្មែរ

– អក្សរខ្មែររុងរឿងដោយសារខ្មែរ
ពុំហ៊ានបំបែរឲ្យភ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស
ពុំហ៊ានបង្ខូសឲ្យខូចបង់។
– ជនខ្មែរស្រុះគ្នាលើកតម្កើង
ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ
ខំប្រឹងតម្រង់អក្សរជាតិ។
– អក្សរវិបត្តិជាតិវិបត្តិ
ខ្វាយខ្វាត់រាត់រាយក្លាយឃ្លៀងឃ្លាត
ហេតុនេះខ្មែរយើងកុំរវាត
ត្រូវរក្សាជាតិឲ្យរឹងប៉ឹង។
– បើដឹងមិនដល់កុំធ្វើចេះ
ចំណេះតិចតួចស្ដួចស្ដើងស្ដឹង
បើចង់ច្បាស់លាស់ត្រូវខំប្រឹង
កុំដេកសម្ងំឲ្យចេះឯង។
– ចំណេះកើតមានព្រោះការរៀន
កម្ជិលអៀនប្រៀនកុំសម្ដែង
ធ្វើឲ្យគេស្ញើចគេកោតក្រែង
ស្លាក់ស្លែងទេកុំរិះគន់គេ។

– ត្រូវរិះគន់ខ្លួនឯងជាមុន
កុំឲ្យស៊ិយស៊ុនខុសទទេ
បើឆ្ងល់ពុំយល់ត្រូវសួរគេ
ឥតថោកអ្វីទេថ្លៃទេតើ។
– បុរាណថាថោកអីនឹងដៃ
ថ្លៃអីនឹងមាត់ពោលសើរើ
រៀនទៅសួរទៅទើបគ្រាន់បើ
អើពើចង់ចេះប្រសើរណាស់។
– ចាស់ថាបើល្ងង់កុំធ្វើចេះ
បើមានចំណេះឲ្យជាក់ច្បាស់
បើស្តើងហើយចង់ឲ្យបានក្រាស់
ត្រូវថែមកម្រាស់ផ្សំសាច់គ្នា។
– អបស្ទបប៉ះប៉ុនយកកម្រាស់
កុំចាំងកុំប្រាស់ហួសមាត្រា
ប៉ះផ្សំផ្គុំភ្ជិតទើបកើតជា
ទោលឬបន្ទារមួនជាងមុន។
– បើចេះអក្សរនិងភាសា
នៃជាតិណាៗកុំជ្រុលស៊ុន
ងាប់ស័ព្ទប្រែស្រាយក្លាយជាប់កុន
សុនត្រុនប្រែស្រាយឃ្លាតក្តីពិត។
– កាលដែលប្រារព្ធនឹងប្រែស្រាយ
ត្រូវគិតនាយអាយដោយពិនិត្យ
ឲ្យឃើញសេចក្តីជាខ្មែរពិត
សឹមប្រែកុំផ្ចិតតាមពាក្យគេ។

– ត្រូវប្រែឲ្យមកជាសេចក្ដី
ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្ដាប់យល់មិនឆ្ងល់ទើបហៅប្រែ
ត្រឹមត្រូវតាមរូបសេចក្ដីពិត។
– អ្នករៀនភាសាជនបរទេស
ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត
ប្រែផ្ចិតឲ្យចំតាមរូបស័ព្ទ។
– ភ្លេចនឹកគិតមកភាសាខ្មែរ
ឲ្យយល់សំនួនដែលងាយស្ដាប់
សម្លឹងសង្កេតតែរូបស័ព្ទ
ក៏ស្រាប់តែប្រែខុសទាំងស្រុង។
– អ្នករៀនសំស្ក្រឹតឬបាលី
ប្រែខុសសេចក្ដីព្រោះភ័ន្តផុង
យល់ខុសទទេទាំងដើមចុង
ចូលក្នុងរឹងស៊ុងខ្មាសអ្នកផង។
– តិដ្ឋៈបាលីប្រែថាឈរ
អ្នករៀនឈ្លក់វរអន់ម្ដងៗ
ត្រង់មានសេចក្ដីថាស្ងួនគ្រង
ប្រែផ្ដងថាឈរនៅងាប់ស័ព្ទ។
– បារាំង «ពរ៍តេស្សួរឡាតែត» (porter sur la tète)
ខ្មែរផ្ទេតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឲ្យគ្នាស្ដាប់
បង្គាប់ថាឲ្យកាន់លើក្បាល។

– មិនប្រាប់ឲ្យគ្នាដឹងថាទូល
នេះហើយស្រមូលពុំត្រកាល
ពាក្យខ្មែរថាទូលក៏លើក្បាល
ត្រអាលប្រែខុសពីពាក្យខ្លួន។
– តែងកាព្យឲ្យត្រូវតាមសម្ពស្ស
តាមកាព្យចាស់ៗដែលមានចួន
កុំចេះតែតែងតាមចិត្តខ្លួន
ឲ្យកាប់មានចួនខុសតម្រា។
– ពាក្យអឺយនិងអើយ[១] សូរផ្សេងគ្នា
ដូចជាប្អូនអើយ[២] ម្ដេចឡើយថា
ស្ដាប់បងមិនឮឬស្ងួនភ្ងា
ធ្វើជាមិនឮព្រោះរឹងខ្លួន។
– ព្រះបាទសម្ដេចព្រះហរិរក្ស
ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
ក្នុងកាព្យព្រះអង្គដែលមានចួន
សំនួនសម្ពស្សឥតមានឆ្គង។
– កវីគួរតែយកតម្រាប់
ពុំគួរប្រញាប់កាត់រំលង
រំលុបបែបនោះមិនត្រាប់ត្រង
ខុសពីបំណងអ្នកប្រាជ្ញចាស់។
– មានអ្នកតែងកាព្យខ្លះហ៊ានថា
ម្ដេចមិនវាចាឲ្យជាក់ច្បាស់

---

១ អានថា អ្អើយ កុំថា អើយ ឬ អឺយ។
២ អានថា ប្អូនអ្អើយ ឬ ប្អូនណើយ កុំថា ប្អូនអឺយ។

ប្រើជាកិរិយាស័ព្ទខុសណាស់
គួរផ្លាស់សំដីនេះចោលចេញ។

**ជ.ណ**

# នៅអាស្រមមនោរម

ពេលព្រះសុរិយាជ្រៀងជ្រេ ហៀបអស្ដង្គត នាថ្ងៃមួយ សម្ដេចព្រះសង្ឃរាជ ព្រះអង្គទ្រង់គង់នៅក្នុងទីលានអាស្រមមនោរម សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជិតវត្តកំណើតនៃព្រះអង្គ សម្ដេចទ្រង់យាងសន្សឹមៗ ទតមើលដំណាំផ្សេងៗ ដែលព្រះអង្គបានដាំពីអាទិត្យមុន។ ព្រះកាយវិការនេះសមដូចពុទ្ធភាសិតមួយថែងថា៖

១ – អនត្ថំ បរិវជ្ជេតំ អត្ថំ គណ្ហាតិ បណ្ឌិតោ។ បណ្ឌិតរមែងវៀរការដែលមិនមានប្រយោជន៍ កាន់យកតែការដែលមានប្រយោជន៍។

តាមពិតសម្ដេច តាំងពីយុវវ័យមិនដែលបង្ហើរពេលវេលាចោលឡើយ បើព្រះអង្គមិនធ្វើធម៌ ក៏ព្រះអង្គធ្វើកិច្ចការអក្សរសាស្ត្រ ឬ កិច្ចសាធារណៈដែរ មិនមែនព្រះអង្គយាងទៅអាស្រមមនោរម ដើម្បីក្រសាលព្រះទ័យដូចជាជនធម្មតាឡើយ។ ព្រះអង្គតែងយកព្រះរាជហឫទ័យទុកដាក់នឹងបញ្ហាទឹក សម្រាប់អ្នកស្រុកនៅទីនោះ។ អាស្រ័យដូច្នេះហើយ ទើបព្រះអង្គជីកស្រះដ៏ធំល្វឹងល្វើយ គួរជាទីត្រេកត្រអាលនៃមនុស្សលោក។

ក្នុងពេលព្រះអង្គកំពុងគង់ទតមើលទម្រង់ស្រះ មានកុមារម្នាក់ឈ្មោះគង់-សំផល ដើរខិនៗតម្រង់ទៅរកព្រះអង្គ។ ពេលនោះ សម្ដេចក៏បន្លឺសូរសីហនាថ៖

– " ម្នាលចៅប្រុស មកទីនេះមានកិច្ចការអ្វីដែរ? "

កុមារសំផល ក្រោយពីក្រាបថ្វាយបង្គំហើយ ក៏លើកដៃប្រណម្យ ឆ្លើយតបទៅកាន់ព្រះនរបតី ដោយសម្លេងថ្នមៗ៖

– " ក្រាបទូលសម្ដេចដ៏ចម្រើន ទូលព្រះបង្គំមកនេះ ដោយមានការងឿងឆ្ងល់សម្បើមណាស់ ហើយជជែកគ្នាមិនដាច់ស្រេចសោះព្រះអង្គ "

– " ឆ្ងល់រឿងអ្វីចៅប្រុសថាមកមើល៍ មិនទាន់តានៅមានជីវិត! " ភ្លាមនោះកុមារក៏ក្រាបទូល៖

– " បពិត្រសម្ដេចដ៏ជាទីគោរព! ទូលព្រះបង្គំឆ្ងល់ថា តើបុព្វហេតុនៃអរិយធម៌ខ្មែរ មកពីអ្វីទៅព្រះអង្គ? " សំនួរនេះ ញ៉ាំងព្រះចិន្ដាព្រះអង្គឲ្យសោមនស្សក្រៃលែង ហើយព្រះអង្គតបៈ

– " សាធុ! សាធុចៅ! ចៅឯងនេះចេះចង់ដឹងដូច្នេះ តាត្រេកអរណាស់ តាមិនចង់ឃើញមនុស្សល្ងង់ខ្លៅឡើយ មិនចង់ចួបមនុស្សក្រល្ហេមល្ហាមគឺចង់ឲ្យមានចំណេះ មានទ្រព្យ ល្មមចាយវាយដូចគ្នា ព្រោះយើងជាមនុស្សដូចគ្នា . . . ។

ចៅ! បុព្វហេតុនៃអរិយធម៌ខ្មែរនេះ គ្មានមកពីណាក្រៅពីសាសនាឡើយ សាសនាបាននាំមកនូវផលប្រយោជន៍ច្រើនណាស់ ដល់មនុស្សលោកយើងនេះ។ តើចៅស្ដាប់បានឬទេ? បើមិនបានកុំលាក់លៀមប្រាប់លោកតាចុះ លោកតានឹងពន្យល់ឯងឲ្យស្គាល់យ៉ាងច្បាស់លាស់ ឲ្យអស់ការសង្ស័យណា៎ ចៅប្រុស!" ពេលនោះសំផលកុមារ មានចិត្តរីករាយ ហើយក្រាបបង្គំទូលទៅព្រះអង្គវិញ៖

– " ព្រះករុណាថ្លៃវិសេស! ទូលព្រះបង្គំអស់សង្ស័យហើយ តែខ្ញុំព្រះអង្គខ្លាចភ្លេចទៅថ្ងៃមុនទៀត ព្រោះសតិខ្ញុំព្រះករុណាទន់ខ្សោយណាស់ទានប្រោស!" ។

– " អឺមិនអីទេចៅ! បើឯងខ្លាចភ្លេចឬស្រពេចស្រពិល ចូរចៅទៅរកមេរៀនប្រវត្តិសាស្ត្ររបស់ ព្រះវិរិយបណ្ឌិតោភិក្ខុ ប៉ាង-ខាត់ ដែលបង្រៀនពួកនិស្សិតនៃវិជ្ជាឋានអប់រំខាងអក្សរសាស្ត្រ មកអាននិងទុកជាឯកសារទៅ ព្រោះលោកជាអ្នកស្រាវជ្រាវមួយដ៏ចំណានមិនអាចកាត់តម្លៃបានទេ . . . ណ្ហើយបើចៅអស់ការហើយគួរត្រឡប់ទៅវិញចុះ ហើយខិតខំរៀនសូត្រឲ្យមែនទែន . . . ទាន់វ័យក្មេងខ្ចី ដើម្បីញ៉ាំងជីវភាពចៅឲ្យថ្លៃថ្នូរនឹងគេ! ចូរចំរើន! "

– " សាធុ! ព្រះអង្គដ៏មានបុណ្យ! សែនសប្បាយចិត្តណាស់ ដែលបានកើតមកជួបនឹងព្រះអង្គ មានព្រះទ័យប្រោសប្រណីជនល្ងិតល្ងង់ឥតរើសមុខ ឬ

ពេលវេលាដូច្នេះ ខ្ញុំព្រះករុណានឹងទៅរកឯកសារនោះ មកទុកប្រចាំគ្រួសារមិនខាន . . . ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំព្រះអង្គសិនហើយ . . ."

– " អឺទៅចុះចៅប្រុស! អានច្រើនចំរើនវិជ្ជា "

ក្រោយពេលសំផលកុមារចេញផុតទៅ សម្តេចព្រះសង្ឃរាជ ជាទីគោរពនៃយើងរាល់គ្នា ព្រះអង្គស្តេចយាងចូលអាស្រមមនោរមវិញ ដើម្បីពិនិត្យពាក្យថ្មីដែលព្រះអង្គបម្រុងនឹងបន្ថែមទៅក្នុងវចនានុក្រមទៀត។

ចំណែក គង់-សំផល កុមារក៏បានធ្វើដំណើរទៅកាន់គេហស្ថានវិញដោយសុវត្ថិភាព។ ប៉ុន្មានថ្ងៃបន្ទាប់មក កុមារនេះបានទទួលមេរៀនប្រវត្តិអក្សរសាស្ត្រ របស់ព្រះភិក្ខុ ប៉ាង-ខាត់ ដូចក្តីបំណងមែន។ កុមារអានបណ្តើរញញឹមបណ្តើរ ដោយពេញចិត្តរបស់ខ្លួនពេក។ អត្ថន័យនៃមេរៀននោះមានសេចក្តី៖

- កថាទី ១ -

## បុព្វហេតុអរិយធម៌ខ្មែរ

ក្នុងការសិក្សាអរិយធម៌ យើងគួរស្គាល់បុព្វហេតុដែលនាំឲ្យកើតអរិយធម៌នេះឡើង។ អ្នកប្រាជ្ញទូទៅតែងមានសេចក្តីយល់ថា អរិយធម៌គ្រប់ប្រការតែងកើតមកពីសាសនា។ សាសនាបុរាណដូចជា សាសនាឥសិប៊ិត៍បាប៊ីឡូនី ហេព្រឺ ប៉ារស៊ី ឬសាសនាធំៗមាន សាសនាព្រាហ្មណ៍ ពុទ្ធសាសនា សាសនាគ្រិស្ត សាសនាឥស្លាម ប៉ុណ្ណោះជាដើម សុទ្ធតែជាថ្នាលបណ្តុះវិជ្ជាគ្រប់ប្រការ ដែលមូលហេតុឲ្យកើតអរិយធម៌ឡើងក្នុងលោក។

ប្រទេសទាំងឡាយ ដែលមានសេចក្តីចំរើនលូតលាស់ឡើង ក៏ព្រោះតែមានវិជ្ជាសាសនាជាដើមចម។ អ្នកប្រវត្តិសាស្ត្រជប៉ុនម្នាក់បានពោលសរសើរទុកថា៖ ពុទ្ធសាសនា បាននាំសេចក្តីចម្រើនមកឲ្យប្រទេសជប៉ុន។ សេចក្តីចម្រើនជឿនលឿនទៅមុខគ្រប់ផ្នែកនៃប្រទេសជប៉ុនដូច ស្ថាបត្យកម្ម សិល្បកម្ម ហត្ថកម្ម ឧស្សាហកម្ម រហូតទៅដល់តួរ្យតន្ត្រីមានប៉ុណ្ណោះជាដើម

សុទ្ធតែកើតឡើងដោយអាស្រ័យពុទ្ធសាសនា។ ដូច្នេះយើងគួរចូលចិត្តថា ពុទ្ធសាសនា មិនមែនមានតម្លៃតែចំពោះតែការប្រតិបត្តិតាមផ្លូវចិត្តតែប៉ុណ្ណឹងទេ មានតម្លៃដល់ការជឿនលឿនទៅមុខនៃអរិយធម៌ខាងផ្លូវលោកគ្រប់ផ្នែកទៀតផង។

សេចក្ដីពិត វិជ្ជាសាសនាមានតម្លៃខ្ពង់ខ្ពស់ណាស់ សមគួរដល់យើងគ្រប់គ្នាហ៊ានលះបង់ពេលវេលាសប្បាយដើម្បីខំសិក្សា ព្រោះជារឿងដែលប្រដៅមនុស្សឲ្យប្រព្រឹត្តិល្អ នាំឲ្យកើតជម្មចរិយាប្រពៃណីល្អ ទំនៀមទម្លាប់ល្អនាំឲ្យបន្ទោបង់ក្ដីទុក្ខ ហើយនាំឲ្យមានក្ដីសុខក្សេមក្សាន្តពោលគឺ វិជ្ជាសាសនាជាប្រទីបអុចទ្រោលបំភ្លឺលោកមើលផ្លូវដើរក្នុងជីវិតគ្រប់ៗគ្នា ហើយគេចកុំឲ្យប៉ះទង្គិចគ្នា ឲ្យចេះ តែបានក្ដីសុខចំរុងចម្រើន ជាមួយគ្នារអឹករអឺនរៀយរហូតទៅនៅនាពេលងងឹតនេះ។ តម្លៃសាសនាដូចបានពោលនេះអ្នកប្រាជ្ញរ៉ាប់រងទូទៅ ហើយអ្នកផងក៏បានដឹងហើយដែរថា តម្លៃនេះមិនមែនមានតែប៉ុណ្ណោះទេ មានច្រើនលើសលុបនឹងគណនាត្រារាប់ឲ្យអស់ជើងតទៅទៀត គឺសេចក្ដីចំរើនគ្រប់ប្រការ របស់មនុស្សលោកសព្វថ្ងៃនេះ សុទ្ធតែកើតចេញមកពីសាសនាទាំងអស់ សូម្បីតែពេទ្យសាស្ត្រដែលគេច្រើនតែចូលចិត្តថាជារបស់ថ្មីក៏ដោយ ក៏នៅ តែមានការទាក់ទងពីសាសនា ព្រោះវិជ្ជាផ្នែកនេះកើតមកពីអ្នកគន់គិតខាងសាសនាច្រើនអ្នកដែរ។

សាសនាជាថ្នាលបណ្ដុះការសិក្សា ព្រោះមានតែវិជ្ជាមួយទេនៅក្នុងលោក គឺវិជ្ជាសាសនា ដែលមនុស្សលោកចូលចិត្តជួញរវល់បំផុតតាំងពីបុរាណកាលនាយមក។ ទីឋានសាសនា គ្រប់សាសនា ដូចវត្តអារាមនៅប្រទេសខ្មែរយើងជាដើម ជាបឋមសាលា គឺសាលាដើមបំផុតនៃពិភពលោក ជាមន្ទីរព្យាបាលរោគ ដើមបំផុតនៃពិភពលោក មើលរោគល្ងង់ខ្លៅគឺអវិជ្ជា បំបើកភ្នែកខ្វាក់ មនុស្សលោកគឺឲ្យមានវិជ្ជា មើលឃើញសេចក្ដីពិតរបស់លោក មើលរោគរាងកាយ ឯលោកគ្រូដើមគឺអ្នកបួសក្នុងសាសនា ព្យាបាល

ទទេ បង្រៀនទទេ។ មួយទៀតសាសនាជាសង្គមដើមនៃមនុស្សលោក ជាទីឋានជួបសន្ទនាគ្នាសម្រាប់ផ្លាស់ប្តូរសេចក្តីយល់ឃើញគ្នាទៅវិញទៅមក ជារមណីយដ្ឋានបន្ទោបង់សេចក្តីទុក្ខក្តៅក្រហាយ ជាវិជ្ជាឋានបណ្តុះវិជ្ជាគ្រប់ប្រភេទ មានវិជ្ជាឋាន ស្ថាបត្យកម្មជាដើម ព្រោះមនុស្សត្រូវការសំណង់ល្អវិសេសឆើតឆាយ សម្រាប់ទុកជាជម្រកអ្នកដែលខ្លួនគួរគោរពបូជា។ រួមសេចក្តីខ្លី ទីឋានសាសនាជាវិជ្ជាឋាននាំឲ្យកើតការរចនាដ៏វិសេស សោភ័ណភាពដ៏ប្រណីតបញ្ចង់ គឺការលំអឥតខ្ចោះគ្រប់ប្រការ។

នៅប្រទេសខ្មែរ ដែលជាអ្នកកាន់ពុទ្ធសាសនាម៉ឺងម៉ាត់មួយ យើងបានឃើញអរិយធម៌ ដែលកើតចេញពីសាសនាយ៉ាងច្បាស់លាស់ ដូចជាប្រាង្គប្រាសាទ រាជដ្ឋាននៅទីឋានមហានគរជាដើម នៅប្រទេសដទៃទៀត ដូចប្រទេសឥស៊ីបត៍ ប្រទេសឥណ្ឌា ប្រទេសចិនជាដើម ក៏អ្នកផងបានឃើញអរិយធម៌ ដែលកើតចេញពីសាសនាពិតប្រាកដដែរ ពោលងាយៗ គឺកាលដើមមិនមានសាលារៀន វត្តជាសាលារៀន កាលដើមមិនមានមន្ទីរពេទ្យ វត្តជាមន្ទីរពេទ្យ ។ល។ ឯឫសគល់សង្គមខ្មែរពីបុរាណ ក៏កើតចេញពីសាសនាដែរ។ ដោយហេតុនេះវិជ្ជាសាសនាមានតម្លៃនឹងកាត់ថ្លៃពុំបាន ព្រោះជាមេអរិយធម៌ទូទៅ។

x x x

លុះអានចប់ហើយ សំផលមានចិត្តរីករាយខុសប្រក្រតី ចេះតែទន្ទេញមិនដាច់ពីមាត់ថា៖

២ – អ្នកប្រាជ្ញតែងសន្សំនូវអ្នកប្រាជ្ញដូចគ្នា តែងស្រលាញ់មនុស្សដូចគ្នា មិនចេះលាក់លៀមនូវការណាប្រសើរឡើយ ហើយតែងដឹកនាំអ្នកផងឲ្យឈានទៅរកសេចក្តីចំរើន។

៣ – បុព្វហេតុអរិយធម៌ខ្មែរ បើអ្នកផងបានក្រេបហើយមុខជាចង់ក្រេបទៀត មិនចេះជិនណាយ។

៤ – វិទ្យាសាស្ត្រជាកូនអកតញ្ញូនៃទស្សនវិជ្ជា។

៥ – ឱខ្លួនអញអើយ កើតមកតោកយ៉ាកលំបាកយ៉ាងនេះ ធ្វើម្តេចហ្ន៎! នឹងបានសិក្សាឲ្យមានចំណេះខ្ពង់ខ្ពស់ដូចព្រះអង្គបាន! តែណ្ហើយចុះត្រូវតែធ្វើតាមព្រះពុទ្ធឱវាទនៃព្រះអង្គ ព្រោះជីវិតត្រូវបេញមុខតស៊ូ, ការតស៊ូក៏ព្រោះជីវិត។

គិតឃើញដូច្នេះហើយកុមារសំផល ក៏ខិតខំប្រឹងប្រែងស្វែងរកប្រាក់ផងសិក្សាផង រហូតបានប្រឡងជាប់ជានិស្សិតសាស្ត្រាចារ្យដូចបំណង។

សម្តេចព្រះសង្ឃរាជ ព្រះអង្គជួញក្រៃលែងនូវការអប់រំយុវៈដែលសំណាក់ក្នុងវត្តអារាម ព្រោះសម្តេចទ្រង់ឈ្វេងយល់ថា៖

៦ – ការសិក្សាជាអង្គការ របស់ជាតិ។

៧ – រូបកាយតែងចាស់ជរា, ឯកេរ្តិ៍ឈ្មោះល្អមិនចេះចាស់ជរាឡើយ, ទាំងធម៌សប្បុរសក៏មិនចេះចាស់ជរាដែរ។

៨ – បើចេញពីវត្តទៅវិញ យ៉ាងហោចណាស់ឲ្យចេះធម៌អាថ៌ខ្លះ ដើម្បីចូលក្នុងពិធីបុណ្យនឹងគេ កុំឲ្យអង្គុយទុកមាត់ស្ងៀម។

ដោយព្រះអង្គជាប់ព្រះទ័យ ចង់ឲ្យយុវជនបានសេចក្តីសុខក្សេមក្សាន្ត ទើបព្រះអង្គនិពន្ធកំណាព្យមួយស្តីអំពីការសេពគប់ ទុកគ្រាន់ជាប្រទីបបំភ្លឺផ្លូវទៅកាន់ក្តីសុខសាន្ត។ តើកំណាព្យនេះមានខ្លឹមសារយ៉ាងណាខ្លះហ្ន៎?

x x x

| គេនិយាយត្រូវគិត តែកុំទាន់វិនិច្ឆ័យ |
|---|

# ការសេពគប់

គប់ពាលរែងពាលទៅរកខុស
គប់ប្រាជ្ញប្រុសរែងបានត្រូវ
គប់មិត្តអបល័ក្ខណ៍រែងអាស្រូវ
ខុសត្រូវកើតពីការសេពគប់។
គួរជ្រើសរើសរកជនប្រុសស្រី
តើមានធម៌អ្វីជាប្រភព
បើឃើញច្បាស់ហើយគួរសេពគប់
ឬត្រូវតែឈប់កុំរវល់។
បើតាមឱវាទព្រះសម្ពុទ្ធ
វិសុទ្ធទ្រង់ធម៌និរមល
គួរជ្រាបថាបើឃើញបុគ្គល
យល់ខុសពុំគួរសេពគប់ឡើយ។
សូវនៅម្នាក់ឯងប្រសើរជាង
គួរជៀសគួរវាងជនតោះតើយ
មិនកាន់តាមធម៌ជាកោះត្រើយ
ព្រងើយដោយយល់ថាខ្លួនត្រូវ។

សម្តេចព្រះសង្ឃរាជ
ជួន ណាត ជោតញ្ញាណោ

## - កថាទី ២ -

## ឧបាយមិនស្លាប់

សម័យថ្ងៃមួយ សាមណេរ ស្វាយ-សាឯម ចូលក្រាបថ្វាយបង្គំ សម្ដេចព្រះសង្ឃរាជ ហើយទូលសួរចំពោះព្រះអង្គថា៖

–បពិត្រសម្ដេចជាអម្ចាស់ ទូលព្រះបង្គំចង់ដឹងថា តើឧបាយអ្វីទៅដែលមិនស្លាប់?

ពេលនោះសម្ដេចជាអម្ចាស់ ទ្រង់មានព្រះឱវាទទៅកាន់សាមណេរ៖

៩ – ម្នាលសាមណេរ! « ការមិនធ្វេសស្មារតី ជាឧបាយមិនស្លាប់។ »

១០ – ការធ្វេសស្មារតី ជាឧបាយស្លាប់។

ព្រោះថា ក្នុងលោកសន្និវាសនេះសម្បូរដោយមនុស្សឆបោកមនុស្ស ដូចជាសហករណ៍នៅស្រុកលោកតា ត្រូវអន្តរាយអស់ ព្រោះតែធ្វេសប្រហែសរហូតដល់ប្រធានរត់បាត់។ សាមណេរក៏សួរថា តើរឿងនេះមានដំណើរយ៉ាងណាខ្លះព្រះអង្គ? សម្ដេចក៏មានព្រះបន្ទូលរាយរាប់រឿងនោះថា៖

នៅសង្កាត់រកាកោះ មានសហករណ៍យើងមួយឈ្មោះ រកាកោះ។ សហករណ៍នេះច្រើនតែទិញស្ករដែលអ្នកធ្វើបានមក។ ការទិញនេះ ខ្លះក៏ឲ្យប្រាក់មុន ខ្លះក៏ទុកសិនដោយប្រធានគ្មានចេញបង្កាន់ដៃអ្វីឲ្យម្ចាស់ស្ករទេ។ រីឯអ្នកម្ចាស់របស់ក៏មិនទាររកបង្កាន់ដៃដែរ ព្រោះតែការទុកចិត្តគ្នា។

លុះមកដល់ឆ្នាំ ១៩៦៩ ប្រធានសហករណ៍នោះយកប្រាក់រាជការអស់ច្រើនសែន។ អ្នកស្រុកដឹងការណ៍មិនស្រួលក៏នាំគ្នាជ្រួលច្របល់ តែមិនមានប្រយោជន៍សោះព្រោះថា៖

១១ – អ្នកធ្វេសស្មារតី ស្លាប់គំនិត ទោះបីមានជីវិតរស់នៅឡើយ ក៏ទុកដូចជាស្លាប់ស្រេចទៅហើយ។

ប៉ុន្មានថ្ងៃក្រោយមកប្រធានកំហិលនោះ ក៏រត់បាត់មិនដឹងធ្លាយច្រកណា ព្រមទាំងស្ពាយប្រាក់កាសយកទៅជាមួយផង។ ចំណែកម្ចាស់ស្ករក៏ស្រែកយំ

លែងចេញ។ រីឯអ្នកដែលមានគំនិតគឺទារបង្កាន់ដៃត្រឹមត្រូវ រាជការមានសមត្ថកិច្ចបានជួយសងថ្លៃរបស់នោះតាមចំណែកខ្លួន ព្រោះថា៖

១២ – អ្នកដែលមិនធ្វេសស្មារតី មិនស្លាប់គំនិត ទោះបីស្លាប់បាត់ទៅហើយ ក៏ទុកដូចជានៅរស់។

យ៉ាងណាមិញ កិច្ចការអ្វីក៏ដោយបុគ្គលមិនគួរធ្វេសប្រហែសសោះឡើយ ព្រោះមនុស្សយើងជួនល្អ ជួនអាក្រក់ រកស្មានមិនត្រូវ ប្រៀបបាននឹងទឹកភ្លៀងដែរ។ នេនអើយ! ចូរនេនខិតខំសិក្សាក្បួនច្បាប់ ផ្លូវលោក ផ្លូវធម៌ ឲ្យល្អិតល្អន់កុំបីវាយមាយក្រែងនាំឲ្យខូចសាសនារបស់ផងយើង! ពេលនោះសាមណេរក៏ក្រាបទូលព្រះអង្គវិញ៖

– ក្រាបទូលសម្ដេចជាអម្ចាស់! ទូលព្រះបង្គំនឹងគោរពតាមឱវាទ ព្រះអង្គមិនខាន។

– សាធុ! សាមណេរដ៏ចម្រើន! ចៅធ្វើនេះហៅពេញជាត្រូវណាស់, ព្រោះថា៖

១៣ – បំណាច់កើតមកជាមនុស្ស កុំធ្វើខ្លួនឲ្យជាអ្នកបំព្រៃលោក។

១៤ – កើតមកជាកូនប្រុស ត្រូវតែខំប្រឹងបំពេញករណីយកិច្ចលុះត្រាតែបានសម្រេច។ ការអ្វីមិនទាន់សម្រេច កុំអាលប្រញាប់ពោលអួត។

១៥ – ប្រាំបួនទ័ល ដប់ទ័ល កុំឲ្យទ័លគំនិត។

ដោយហេតុល្ងីតល្ងង់ មិនបានរៀនសូត្រហើយ ទើបប្រធានលួចរត់យកទ្រព្យខ្លួនអស់ ហើយទើបស្ដាយក្រោយ។ បើតែយ៉ាងហ្នឹង ព្រះឯណាប្រោសយើងកើត បើយើងគ្មាននិស្ស័យ ពោលគឺបញ្ញាស្មារតីផងនោះ! ដោយប្រការថា៖

១៦ – ជីវិតរាល់រូបតិចតួចណាស់, ប៉ុន្តែយើងត្រូវប្រឹងរៀន ប្រឹងរក ប្រឹងគិត ប្រឹងប្រព្រឹត្តិល្អ ហាក់ដូចជាយើងនឹងមានជីវិតរស់នៅរាប់ពាន់ឆ្នាំ។

១៧ – កិច្ចការដំបូង តែងតែមានទាស់ខុសខ្លះ, លុះត្រាតែស៊ប់ស៊ាំ

ទើបមិនភ្លាត់ភ្លាំងខុសទៀត។

១៨ – បានត្រូវ មកពីស្គាល់ខុស, បើមិនដូច្នោះទេរកត្រូវពុំឃើញឡើយ។

១៩ – ឃើញគេថ្កុំថ្កើង កុំចចើងតាមគេ ហួសមាឌខ្លួន, ប៉ុន្តែមិនត្រូវបន្ធូរបន្ថយព្យាយាមឡើយ។

២០ – កុំថ្កោលទោសគេពុំពិនិត្យ កុំគិតខ្លួនឯងថាប្រពៃ កុំធ្វេសប្រហែសពាក្យសំដី នាំឲ្យមានភ័យដល់អាត្មា។

២១ – តណ្ហាជាហេតុ, សេចក្តីសុខជាផល, ឧបាយរលត់ជាហេតុ, និរោធធម៌ (ធម៌រំលត់ទុក្ខ) ជាផល។ នេះជាសច្ចធម៌ពិតណាស់។

សេចក្តីនេះជ្រាលជ្រៅវែងឆ្ងាយបន្តិច តែបើនេនខំរិះគិតវានៅលើគោកសោះ ហើយគ្មានអ្វីដែលធំជាងខួរក្បាលយើងទេ ... ចូរនេនចាំចុះ។

– ព្រះករុណាថ្លៃវិសេស! ទទួលព្រះរាជឱវាទ!

– អឺ! ទៅរករំលឹកមេរៀនចុះ! ប្រយ័ត្នអាចារ្យស្តីបន្ទោសព្រោះខ្លួនមិនចេះចាំ! តែចូរចាំថា៖

២២ – ប្រទូសទៅរកអ្នកឥតទោស រមែងធ្លាក់ទោសមកលើខ្លួនវិញ។

២៣ – ជាតិប្រេងនិងទឹកមិនស៊ីគ្នាយ៉ាងណា បុណ្យនិងបាបក៏យ៉ាងនោះដែរ។

សម្តេចមានព្រះរាជបន្ទូលចប់ហើយ ទើបព្រះអង្គយាងចូលទៅកាន់កន្លែងថ្វាយបង្គំនឹកគុណ ព្រះសម្មាសម្ពុទ្ធដូចសព្វដង។ លុះចប់នមស្ការហើយ ព្រះអង្គទតសៀវភៅផ្សេងៗ ដែលមានប្រយោជន៍សមដូចគាថាក្នុងស្រីហិតោបទេស ចែងទុក៖

២៤ – អ្នកប្រាជ្ញតែងប្រើកាលវេលាឲ្យប្រព្រឹត្តិទៅ ដោយការកំសាន្តកាព្យសាស្ត្រ។ មនុស្សល្ងង់តែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅ ដោយការប្រព្រឹត្តិសេចក្តីវិនាស ដោយការដេក និងដោយការឈ្លោះទាស់ទែង។

x x x

# កតញ្ញូតា
# គាថៈនៃអ្នកដឹកគុណ

(បទ កាកគតិ)

កតញ្ញូតា
មានន័យប្រាប់ថា ជនកតញ្ញូ ត្រូវតែប្រព្រឹត្ត
តាមបែបគំរូ ដែលព្រះជាគ្រូ ប្រាប់ឲ្យតបគុណ។

មាតាបិតា
គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ ជនណាក៏ដោយ
ដែលគេមានគុណ ក៏ជាស្រែបុណ្យ ដែលត្រូវសាបព្រោះ។

បណ្ដុះពូជបុណ្យ
ក្នុងស្រែជាគុណ កុំឲ្យមានមោះ បុណ្យនឹងកើតកើន
ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ កុំលុបគុណចោល។

កុំគ្រាន់តែថា
មាតាបិតា មានគុណជាគោល មាត់ថាត្រូវតប
គុណកុំច្បោលៗ ធ្វើដៃរស្រោលៗ សោះតែគេថា។

ជនអ្នកតបគុណ
ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេសនា សរសើរញឹកញយ
មានក្នុងសាស្ត្រា គម្ពីរដីកា គួរយើងចងចាំ។

ចេះចាំហើយធ្វើ
ដោយចិត្តអើពើ ឲ្យស៊ប់ឲ្យស៊ាំ ឲ្យស្ថិតដឹងគុណ
គុណតែងថែមទាំ ពុំមែនខ្ជិចខ្ជាំង ព្រោះតបគុណទេ។

ជនមានចិត្តខ្សោយ
ច្រើនតែធ្វេសធ្លោយ រមិលគុណគេ អាងព្រេងសំណាង

ពីក្នុងបុព្វេ ប្រហែលធ្វេសទ្វេ ព្រងើយកន្តើយ។
អ្នកប្រាជ្ញប្រាប់ថា
ជនប្រុសស្រីណា លុបគុណចោលហើយ ជនប្រុសស្រីនោះ
ពុំមានសុខស្បើយ យូរប៉ុន្មានឡើយ រែងតែធ្លាក់ខ្លួន។
កំពុងបានសុខ
ស្រាប់តែមានទុក្ខ ចេញមកផ្ទួនៗ ឲ្យផលកំណាច
ឃោរឃៅឥតស្ងួន ទោសមកពីខ្លួន រមិលគុណគេ។
ទេព្ដាគេខឹង
ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ ទោសបច្ចុប្បន្ន
ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ បើមានក៏ផ្អាក។
ទោសរមិលគុណ
រារាំងមុខបុណ្យ ព្រេងឲ្យសម្រាក បង្អង់ឈប់សិន
បាបថ្មីវិបាក ឲ្យផលឥតស្រាក ព្រោះបានឱកាស។
បុណ្យបាបចាស់ថ្មី
តែងតែរំពៃ ពុំមែនផ្ដេសផ្ដាស កាលមានចន្លោះ
ត្រូវពេលសស្រាស ហាក់ដូចប្រកាស ប្រាប់ថាត្រូវអញ។
ចេញមុខផ្ដល់ផល
សុខទុក្ខឲ្យដល់ ជនណាដែលកាញ់ កសាងបង្កើត
កំណើតជាអញ អញជាសម្លាញ់ ត្រូវអញឲ្យផល។
រីបុណ្យឬបាប
ដែលមានសភាព ជាកម្មតែងផ្ដល់ សុខទុក្ខឲ្យជន
អ្នកធ្វើឲ្យដល់ នូវក្ដីដល់រល់ ឬក្ដីសុខសាន្ត។
បាបតែងរារាំង
បុណ្យឲ្យនៅគាំង ផ្អាកសិនពុំបាន ចេញមុខឲ្យផល

| | | |
|---|---|---|
| ជាសុខសម្រាន្ត | អ្នកធ្វើតែងបាន បុណ្យក៏រារាំង | ទទួលរងទុក្ខ។ |
| បាបឲ្យនៅគាំង | ផ្អាកពុំចេញមុខ | ព្រោះមានឱកាស |
| បុណ្យផ្ដល់ក្ដីសុខ | សុទ្ធតែមានមុខ ហេតុនេះគួរជន | ទីទៃពីគ្នា។ |
| កុំនៅទម្រន់ | ក្នុងក្ដីខ្ជិលខ្ជា | គួរកសាងបុណ្យ |
| មានគុណមហិមា | ទើបបានឈ្មោះថា | អ្នកស្រលាញ់ខ្លួន។ |

វត្តឧណ្ណាលោម, ភ្នំពេញ ថ្ងៃទី២៦ ធ្នូ ព.ស. ២៥១២
គ.ស. ១៩៦៨

ព្រះហស្តលេខា
សម្ដេចព្រះសង្ឃរាជ
**ជ.ណ. ជោតញ្ញាណោ**
*ប.អ.ស. - អ.ម.រ.*

X X X

# ព្រះគុណូបការៈដ៏លើសលុបនៃសម្តេច ព្រះសង្ឃរាជថ្នាក់ទី ១ ចំពោះអង្គការខេមរយានកម្ម

សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ **ជួន-ណាត** ព្រះសង្ឃរាជថ្នាក់ទី ១ នៃគណៈមហានិកាយ ព្រះអង្គមានព្រះទ័យស្រលាញ់អក្សរសាស្ត្រជាតិណាស់។ ព្រះអង្គទ្រង់មិនសំចៃព្រះកាយពលដើម្បីនឹងជួយរុញច្រានចលនាខេមរយានកម្ម តាំងពីអង្គការនេះកើតឡើង រហូតទល់ពេលចូលទិវង្គតនៃព្រះអង្គ។

ព្រះអង្គទ្រង់យកព្រះទ័យទុកដាក់ជានិច្ច ចំពោះចលនាខេមរយានកម្ម ចាប់តាំងពីថ្ងៃទី១២ កក្កដា គ.ស. ១៩៦៧ ដែលសហជីវិន វណ្ណ-មូលីវណ្ណ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ និងសហការី បានចូលក្រាបបង្គំគាល់នៅមហាកុដិជាលើកដំបូងបង្អស់ ដើម្បីសុំព្រះអង្គទ្រង់គង់ជាអធិបតីនៃចលនាខេមរយានកម្ម។ ពេលនោះសម្តេចព្រះសង្ឃរាជទ្រង់បានទូន្មានថា "សុំឲ្យចាត់ការនេះឲ្យហ្មត់ចត់ កុំគិតងាយ ពីព្រោះកុំឲ្យខុសចំពោះការសរសេរពាក្យពេចន៍ខ្មែរ ដែលខុសឆ្គងយ៉ាងច្រើនកាលពីមុន ដូចជាការកត់ត្រាហៅឈ្មោះស្រុក ភូមិ ខេត្ត ឬការសរសេរឃើហោលើផ្ទះ ឬកញ្ចប់នំជាដើម។ កំហុសក្នុងការសរសេរពាក្យជាភាសាខ្មែរនេះមានខុសរហូតដល់ទៅ សរសេរបញ្ជីជាតិអត្រានុកូលដ្ឋានជាដើម" ។

សម្តេចព្រះសង្ឃរាជទ្រង់សព្វព្រះទ័យថា នឹងជួយពិនិត្យស្នាដៃផ្សេងៗដែលកើតពីចលនានេះឲ្យតែគណៈកម្មការ ឬអ្នកនិពន្ធ យកមកគាល់ថ្វាយព្រះអង្គផ្ទាល់ចុះ។

ព្រះរាជូបត្ថម្ភទាំងនេះសឲ្យឃើញថា សម្តេចទ្រង់ស្រលាញ់ភាសា និង

អក្សរសាស្ត្រជាតិណាស់ ទោះបីព្រះអង្គមានកិច្ចការមមាញឹកយ៉ាងណាក៏ដោយ ព្រះទ័យព្រះអង្គទ្រង់ជាប់ជំពាក់ជានិច្ច ចំពោះអង្គការយើង ដោយទ្រង់ប្រទានឱវាទផ្សេងៗ ឬក៏ណែនាំក្នុងកិច្ចការយ៉ាងណាដែលនាំឲ្យភាសាជាតិយើង ងើបមុខត្រដែតក្នុងផ្ទៃរាបអន្តរជាតិ។

គណៈកម្មាធិការជាតិ បានលើកព្រះអង្គជា ព្រះអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមក្នុងការណែនាំប្រែពាក្យខ្មែរ ព្រះអង្គទ្រង់បានជួយបកប្រែពាក្យខ្មែរ តាំងពីកំណើតខេមរយានកម្មមកម្ល៉េះ គឺឆ្នាំទី ១ និងទី ២ មានចំនួន ១០.៦៣៩ ពាក្យហើយមកដល់ឆ្នាំទី ៣ មុនទិវង្គតកាលនៃព្រះអង្គបានចំនួន ៦៨៤ ពាក្យទៀត។ សូមបញ្ជាក់ថា ព្រះអង្គទ្រង់មានចំណេះវិជ្ជាខាងបាលីនិងសំស្ក្រឹតជ្រៅជ្រះណាស់ តែព្រះអង្គយកព្រះទ័យទុកដាក់ជាទីបំផុត ចំពោះពាក្យខ្មែរ មានសំនៀងខ្មែរពិតប្រាកដ។ ព្រះអង្គទ្រង់ឆ្លៀតពេលសម្រួលពាក្យបកប្រែ ហើយដោយឆ្នូលពាក្យជាឃ្លាប្រយោគ ឲ្យមកជាខ្មែរទាំងស្រុង មានលក្ខណៈវិទ្យាសាស្ត្រពេញលេញបានចំនួន ៤២០ ពាក្យនៅឆ្នាំទី ១ ។

ឧទាហរណ៍៖

ការខ្វះចម្ងាញ់ ទៅជា កង្វះចម្ងាញ់ - ការភ្ជាប់ ទៅជា បញ្ជាប់

ការឆេះ - ចំហេះ, ការវាយ - វង្វាយ, ការថែទាំ - តំហែទាំ

ការហុច - លំហុច, ការផ្តើមគំនិត - បណ្តើមគំនិត, ការលាត –ល្បាត

ការផ្សៀងផ្ទាត់ - បន្សៀងបន្ទាត់, ការអារ - អំណារ

ឧទាហរណ៍ទាំងអម្បាលម៉ានខាងលើនេះបញ្ជាក់ថា ព្រះអង្គសព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ចំពោះពាក្យខ្មែរសុទ្ធ សមព្រះឋានៈជាអ្នកខ្មែរនិយមពេញទី។

ទោះទ្រង់រវល់នឹងភ្ញៀវ ឬទ្រង់ជាប់រវល់ក្នុងព្រះកិច្ចការយ៉ាងណាក៏ដោយព្រះអង្គទ្រង់ព្រះអនុញ្ញាតសមាជិកអង្គការយើង ឲ្យចូលក្រាបថ្វាយបង្គំ សូមព្រះរាជយោបល់បានគ្រប់ពេលមិនថាយប់ ឬថ្ងៃឡើយ។ ការចូលថ្វាយបង្គំ

គាល់ជាផ្លូវការ នៃអង្គការយើងមានចំនួន ២០០ ដងក្នុងកំឡុងពេលសិក្សា។

សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់សព្វព្រះរាជហឫទ័យចំពោះអក្សរជាតិណាស់ ដោយព្រះអង្គបានគាំទ្រជាទីបំផុតចំពោះអង្គការខេមរយានកម្មសិក្សា ក្រៅពីព្រះរាជយោបល់និងបកប្រែពាក្យខ្មែរ ព្រះអង្គទ្រង់ផ្តល់អត្ថបទជាច្រើនមកពីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃខេមរយានកម្ម ដើម្បីលើកស្ទួយភាសាជាតិ និងទស្សនាវដ្តីខេមរយានកម្មឲ្យមានពន្លឺត្រចះត្រចង់គ្រប់ពេលវេលា។ ព្រះរាជអត្ថបទទាំងនោះមានដូចតទៅ៖

– ទស្សនៈនៃសម្តេចព្រះសង្ឃរាជ ចុះក្នុងទស្សនាវដ្តីឆ្នាំទី ២ លេខ ១

– កំណាព្យ ៖ ការសេពគប់ ........................... លេខ ៤

– កំណាព្យ ៖ រំលឹកអក្សរខ្មែរ ......................... លេខ ៧

– កំណាព្យ ៖ កតញ្ញូតាភារៈនៃអ្នកដឹកគុណ ចុះផ្សាយក្នុងទស្សនាវដ្តីឆ្នាំទី ៣ លេខ ១

ព្រះរាជូបត្ថម្ភទាំងនេះ ទោះបីព្រះអង្គយាងចូលទិវង្គតទៅហើយក៏ដោយ អង្គការយើងនៅតែលើកយកព្រះរាជោវាទទាំងនោះ ទុកជាគតិធម៌ជានិច្ចចំពោះកិច្ចការនៃខេមរយានកម្ម។

គណៈកម្មាធិការជាតិ

**ខេមរយានកម្ម**

X X X

# អនុសាសនោវាទ
# ចំពោះយុវជនអ្នកនៅវត្ត

ហៃពួកយុវជនអ្នកកំសត់
សមអ្នកនឹងឥតមានតម្លៃ
គួរអ្នកកុំភ្លេចវត្តលំនៅ
គួរដឹងគុណវត្តកុំបង្អោច
បើមានគេសួរពីកាលរៀន
អ្នកកុំនិយាយបង្វែងដាន
កុំពោលបង្អួតពួកស្រីៗ
បំផ្លែងបំផ្លើសបំភ្លេចវត្ត
បាយវត្តជាភោជន៍មានព្រលឹង
នាម៉ឺនមន្ត្រីមកពីរាស្ត្រ
បាយផ្ទះបាយវត្តដូចជាគ្នា
ឆ្អែតហើយរៀនសូត្របេះខ្មៅខ្មី
សាធុ ! សូមឲ្យអ្នកបានសុខ
ជាជនសប្បុរសរបស់រដ្ឋ

បើកុំបានវត្តជ្រកអាស្រ័យ
យប់ថ្ងៃហួសទៅឥតប្រយោជន៍។
ទោះអ្នកចេញទៅឆ្ងាយស្រឡោច
ប្រយោជន៍និងផលផ្តល់ពុំខាន។
ចំណេះរបៀនទាំងប៉ុន្មាន
ត្រូវប្រាប់ថាបានចេះព្រោះវត្ត។
ត្រូវស្តីតាមត្រង់កុំបំភ្លាត់
ក្រែងទោសទាញទាត់ឲ្យវិនាស។
គួរនឹករំពឹងកុំទីសទាស
គឺរាស្ត្រឡើងទៅជាមន្ត្រី។
ចំអែតអាត្មាមានជីវី
មុនីកើតមានដោយសារវត្ត។
និរទុក្ខនិរភ័យសិរីភ័ទ្រ
មានបែបមានបទប្រសើរហោង !

សម្តេចព្រះមហាសុមេធាធិបតី

**ជួន ណាត**

ជោតញ្ញាណោ

ថ្ងៃទី ១៦ ឧសភា ១៩៦៣

x x x

# បទវស្សន្តតិលកច្ឆន្ទ

(សម្រាប់សូធ្យបង្ហូតទង់សាសនា)

សូមមើលទង់ជ័យឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺល្អស្រស់
ខៀវលឿងក្រហមព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក។
ប្រទេសតូចធំបានស្ម័គ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង។
ធ្វើជាសញ្ញាទង់ជ័យសាសនា នៃសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចងចាំ នឹកដល់ព្រះអង្គជាអម្ចាស់។
ទោះជាតិផ្សេងគ្នាក៏ត្រូវដឹង សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គីទាំងក្មេងចាស់ ប្រឹងប្រែងឲ្យណាគ្រប់ៗគ្នា។
សូមសាសនាពុទ្ធថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគផ្សាយពេញលោកា ដោយជនជ្រះថ្លារាប់ច្រើនលាន។
មានចិត្តស្នេហាគោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេពតាស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្ដីសុខ។
យើងខេមរជាតិនាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ យើងនឹងបានសុខក្សេមសានត្រាណ។
ព្រមព្រៀងប្រព្រឹត្តតាមធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា។

# រាប់ជាតកឆព្វណ្ណរង្សីទង់សាសនា

(សម្រាប់សូធ្យដាក់ទង់សាសនា)

ក្រុមយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរង់ប្រសើរបវរ
ឆ្មៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ត្រូវជាប្រាំមួយប្រការ ទាំងចាស់កុមារចូរចាំទុកអើយ។

X X X

ព្រះអង្គទ្រង់និពន្ធសម្រាប់ «សាលាអប់រំសីលធម៌» ។



សម្ដេចយាងទស្សនាវត្តនានានៅកម្ពុជាក្រោម កាលពីឆ្នាំ ១៩៣៩ ។ ទ្រង់ថតនៅវត្ត ទីដាម នាក្រុងវ៉ៃ ។ ក្នុងការយាងនេះ ព្រះអង្គបានពន្យល់ទ្រឹស្ដីព្រះពុទ្ធសាសនា ដល់ព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរក្រោមដោយសោមនស្ស។

# សុភាសិតសម្ដេចជាអម្ចាស់

១. ការអម្បាល កុំអាលពោលអួតមុន។
២. ឧបាយកលសើរៗ ពុំស្មើគំនិតជ្រៅ។
៣. កំណាចឈ្លានពាន មានរឿងពុំសូវស្រាក។
៤. សេពគប់ពាល ពាលនាំទៅរកខុស សេពគប់ប្រាជ្ញប្រុស ប្រាជ្ញនាំទៅរកត្រូវ។
៥. សូវនៅម្នាក់ឯង គួរជៀសវាងបាបមិត្ត។
៦. ចិត្តឥតភ្នែក ភ្នែកឥតចិត្ត អ្នកគិតល្អិតទើបអាចយល់បាន។
៧. មើលងាយអ្នកផង នាំឲ្យកន្លងច្បាប់។
៨. រអិលមាត់ ច្រើនតែភ្លាត់ស្មៀត។
៩. សើចក្អាកក្អាយ នាំឲ្យស្ដាយក្រោយ។
១០. កាប់បំពង់រង់ចាំទឹកភ្លៀង ភ្នែកមិនផ្សៀងឃើញមិនសព្វ។
១១. ធ្វើស្រែទាន់មានភ្លៀង ស្រែកច្រៀងទាន់មានភ្លេង។
១២. ពេលត្រូវដើរបែរជាដេក ខ្ជិលហួសពេកនាំឲ្យល្ងង់។
១៣. មានះចចេសក្រៃ អស់តម្លៃគ្មានចំណេញ។
១៤. បំណាច់កើតជាអង្គប្រុស កុំប្រព្រឹត្តខុសពីធម៌ច្បាប់។
១៥. ប្រាំបួនទិញ ដប់ទិញ កុំទិញរបស់ថោក។
១៦. កុំស្ដាយគុម្ពចេកមួយគុម្ព។
១៧. កុំស្ដាយអាចម៍គោមួយគំនរ។
១៨. បើមិនចេះត្រូវសួរគេ កុំមានះយកគ្រាន់បើ។

X X X

សុភាសិតទាំងអស់នេះ ព្រះអង្គតែងមានព្រះបន្ទូលទៅកាន់ពួកយុវជនជារឿយៗ ដើម្បីឲ្យបានទៅជាពលរដ្ឋមួយរូបថ្លៃថ្នូរនឹងគេ កុំឲ្យក្រាញនៅតែ

មួយកន្លែង ត្រូវតែផ្លាស់ដីថ្មី គំនិតថ្មី ទើបរកសុភមង្គលឃើញ មិនគួរគប្បីស្តាយស្រណោះដីកំហិល ដែលមានតែដើមត្នោតឬចេកដូងមួយគុម្ពពីរឡើយ ។ល។

X X X

និគមវចនៈ

ពាក្យផ្ដួនថៃមរបស់ខ្ញុំ

## ចំពោះសសបណ្ឌិតជាតក

សសលក្ខណំ តទា ហិ ចន្ទបណ្ឌលេ តតោ បដ្ឋាយ តញ្ចេវ កប្បំ តិដ្ឋតិ តេជសា ។

ឥទំ និស្សាយ ចនោបិ សោ សសីឥតិនាមកោតស្មា កោចិ សសី និស្វា តស្ស សីលានុមោទវេ ។

រូបជាលក្ខណៈនៃទន្សាយ កើតមាននាមមណ្ឌលនៃព្រះចន្ទ្រ តាំងពីកាលណោះមក[1] ដោយតេជៈនៃព្រះឥន្ទ្រ, រូបទន្សាយនោះឋិតនៅអស់មួយកប្ប។ ព្រោះតែមានរូបទន្សាយនេះ បានជាព្រះចន្ទ្រនោះមាននាមមួយទៀតថា **សសី** ប្រែថា "មានរូបទន្សាយ" ។ ព្រោះហេតុនេះ ជនខ្លះដែលបានឃើញព្រះចន្ទ្រ, គេតែងតែអនុមោទនា ចំពោះគុណធម៌របស់ពោធិសត្វ កាលចាប់កំណើតជាសសបណ្ឌិតនោះ (ដូចជាក្នុងវេលាយប់ ១៥កើត ខែកត្តិក ជាថ្ងៃអកអំបុក សំពះព្រះខែ រៀងរាល់ឆ្នាំជាដើម ជួនកាលមានអាចារ្យ គ្រហស្ថ ឬបព្វជិតទេសនារឿងសសបណ្ឌិតជាតក នេះក្នុងពេលនោះផង)។

---

## អានិសង្សសីល និង ទាន

សីល នានានិសំសស្ស គុណោ លោកេ អនុត្តរោកាជាចិ ឡជិសំ ឧណ្ហំ សក្កស្ស ភវនំ វរំ ។ តស្មា ភគវតោ វុត្តំ សីលគន្ធោ អនុត្តរោ សព្វេសំ គន្ធជាតានំ អញ្ញោ គន្ធោន តាទិសោ ។ ចារិច្ចត្តកាគន្ធោចិ អនុវាតញ្ច វាយតិ សីលគន្ធោ បនេកោវ សព្វទិសាសុ វាយតីតិ។

---

១ កាលពោធិសត្វចាប់កំណើតជាទន្សាយ ហៅថា សសបណ្ឌិត

គុណនៃអានិសង្សសីលនិងទាន ជាគុណធម៌ដ៏ប្រសើរបំផុតក្នុងលោក, ជួនកាលបណ្តាលឲ្យភវនដ្ឋានដ៏ប្រសើររបស់ព្រះឥន្ទ្រក្តៅក៏មានខ្លះ ដូចក្នុងរឿងសសបណ្ឌិតជាតក នេះ (ត្បិតសីលនិងទាននោះឧក្រិដ្ឋក្រៃលែងណាស់) ។ ព្រោះហេតុនោះបានជាព្រះភគវ័តទ្រង់ត្រាស់ថា «សីល-គន្ធ គឺក្លិននៃសីលជាក្លិនក្រអូបប្រសើរ លើសលុបជាងក្លិនក្រអូបឯទៀត (ក្នុងលោក)។ ឯក្លិនដទៃឥតមានក្លិនផ្កា ឬក្លិនខ្លឹមឈើណាមួយក្រអូបដូចក្លិនសីលឡើយ។ សូម្បីក្លិនផ្កា បារិច្ឆត្តកព្រឹក្ស (ក្នុងត្រ័យត្រិង្សសួគ៌) ក៏ក្រអូបបានតែបណ្តោយខ្យល់ប៉ុណ្ណោះឯង, មានតែក្លិនសីលមួយទេ ទើបក្រអូបផ្សព្វផ្សាយក្នុងទិសានុទិសបាន គឺបណ្តោយខ្យល់ក៏ក្រអូប ទទឹងខ្យល់ក៏ក្រអូប ប្រាសខ្យល់ក៏ក្រអូប» ។

(និតមវចនេន បនិមា បញ្ច តាថា ជ.ណ. ជោតញ្ញាណោន សង្ឃរាជេន ខយាមវេ ពុទ្ធសេកា វចិតាមយា) ។

វត្តឧណ្ណាលោម ព្រះរាជធានីភ្នំពេញ

ថ្ងៃចន្ទ ទី១៣ មករា ២៥១២ / ១៩៦៩

សម្តេចព្រះមហាសុមេធាធិបតី

**ជ.ណ. ជោតញ្ញាណោ**

ព្រះសង្ឃរាជគណៈមហានិកាយ

*ប.អ.ស– អ.ម.រ.*

(ស្រង់ចេញពីសៀវភៅសសបណ្ឌិតជាតក ដែលព្រះអង្គរៀបរៀង ដើម្បីចែកផ្សាយជាធម្មទាន, ក្នុងឱកាសពិធីបុណ្យឈាបនកិច្ចសព្វនៃ ព្រះធម្ម

# ឃោសាចារ្យ **អ៊ិត ឥុម** ចៅអធិការវត្តសារាវ័នតេជោភ្នំពេញ)

ខន្តីប្រធាន ប្រសើរលើសទាន ធំក្រៃកន្លង ជាមេអស់ផល
អស់កុសលផង កម្រប៉ិត្តចង បានសីលខន្តី។
(សម្តេចព្រះសង្ឃនាយក គណៈមហានិកាយ ព្រះនាមប្រាក់ហ៊ិន)

# ទំនុកនគររាជ

សូមពួកទេវតា រក្សាមហាក្សត្រយើង
ឲ្យបានរុងរឿង ដោយជ័យមង្គលសិរីសួស្ដី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលបានសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន។
ប្រាសាទសិលា កំបាំងកណ្ដាលព្រៃ
គួរឲ្យស្រមៃ នឹកដល់យសសក្តិមហានគរ
ជាតិខ្មែរដូចថ្ម គង់វង្សនៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ។
គ្រប់វត្តអារាម ឮតែសូរសព្ទធម៌
សូត្រដោយអំណរ រំលឹកគុណពុទ្ធសាសនា
ពួកយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែថ្ងៃណា ទេពតានឹងជួយផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ។

(ទ្រង់និពន្ធពីថ្ងៃ ២០.៧.១៩៤១)

# ទំនុកសរភញ្ញ

សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេពតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុលឲ្យកើតនូវសន្តាន ជាទានប្រសើរអាចកំចាត់
ទុក្ខភ័យចង្រៃឲ្យខ្ចាយបាត់ អារកាត់ទុក្ខទាំងពួងបាន។
សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបុរាណ
នឹងរៀននឹងស្ដាប់នេះចាំបាន ហាត់តាមលំអានបានក្ដីសុខ។
មិនមានសុខណាស្មើក្ដីស្ងាប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្ដីសុខនឹងមានព្រោះធម៌ស្ងប់។
សូមថ្វាយបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងសព្វគ្រប់
ជាក់ជាព្រះត្រ័យរតន៍គួរគោរព ជាសុខត្រជាក់នៃលោកា។
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធគឺជាព្រះសាសនា
សូមគុណត្រ័យរតន៍ជួយខេមរា ឲ្យបានសុខារៀងតទៅ។

(ទ្រង់និពន្ធពី ព.ស. ២៥០០)

# ខ្លឹមសារព្រះត្រៃបិដក
# ឬ
## ព្រះពុទ្ធភាសិតខ្លះក្នុងបរិនិព្វានកាល

ការចាត់ចែងធ្វើពិធីសម្ពោធព្រះត្រ័យបិដក ជាផ្លូវការផង អំពាវនាវឲ្យព្រះសង្ឃនិងពុទ្ធបរិស័ទ ក្នុងព្រះរាជអាណាចក្រ ធ្វើគ្រប់វត្តអារាមក្នុងពេលជាមួយគ្នាផង យ៉ាងនេះ តើដោយយល់ឃើញថា ព្រះត្រៃបិដកជាអ្វី? ព្រះត្រៃបិដកអាចផ្ដល់ផលប្រយោជន៍ដូចម្ដេចខ្លះ?

សេចក្ដីឆ្លើយដោះស្រាយនឹងបញ្ហាខាងលើនេះ សូមពុទ្ធបរិស័ទទាំងឡាយចាំប្រុងស្ដាប់ដូចតទៅនេះ៖

ព្រះត្រៃបិដក គឺជាតួអង្គព្រះសម្មាសម្ពុទ្ធបរមគ្រូហ្នឹងឯងតែម្ដង! ព្រោះព្រះត្រៃបិដកជាធម៌និងវិន័យ ដែលព្រះពុទ្ធជាបរមគ្រូទ្រង់បានសម្ដែង ទ្រង់បានបញ្ញត្តទុកមក ហើយព្រះធម៌និងវិន័យនោះជាតួព្រះសាស្ត្រា គឺជាជំនួសព្រះពុទ្ធជាបរមសាស្ដា ដូចមានពុទ្ធភាសិតក្នុងបរិនិព្វានសូត្រគម្ពីរទីឃនិកាយមហាវគ្គថា ព្រះសម្ពុទ្ធទ្រង់ត្រាស់ហៅព្រះអានន្ទត្ថេរ ជាពុទ្ធបដ្ឋាកមកប្រាប់ថា៖

ម្នាលអានន្ទ, ប្រសិនបើអ្នកទាំងឡាយយល់ឃើញថាបាវចនានេះ គឺពាក្យប្រៀនប្រដៅ ដែលមានគ្រូកន្លងទៅហើយ គឺថា អំណើះតពីគ្រូទៅហើយ ឈ្មោះថាគ្រូរបស់យើងមិនមានឡើយ ម្នាលអានន្ទ, អ្នកកុំយល់ឃើញយ៉ាងនេះឡើយ (ការយល់ឃើញយ៉ាងនេះខុសទេ) ។

ព្រះពុទ្ធជាបរមសាស្ដាទ្រង់បានត្រាស់បញ្ជាក់ថា៖

-ម្នាលអានន្ទ ធម៌ណា វិន័យណា ដែលអញតថាគតបានសម្ដែងហើយបានបញ្ញត្តិហើយ ចំពោះអ្នកផងទាំងឡាយ, កាលបើអំណើះតពីអញតថាគតទៅ ធម៌វិន័យទាំងនោះជាសាស្ដា ជាគ្រូប្រៀនប្រដៅ របស់អ្នកទាំង

ឡាយ។

ពុទ្ធភាសិតខាងលើនេះ គួរពុទ្ធបរិស័ទទាំងឡាយចងចាំក្នុងចិត្ត ហើយយល់ច្បាស់ថា ធម៌វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សម្ដែងហើយបានបញ្ញត្តហើយ សឹងមានក្នុងព្រះត្រៃបិដកទាំងអស់ ព្រះត្រៃបិដកនេះហើយជាសាសនារបស់ព្រះពុទ្ធ ជាតំណាងអង្គនៃព្រះពុទ្ធ ជាព្រះបរមសាស្ដា។

មានពុទ្ធភាសិតមួយបទទៀតជា ពុទ្ធឱវាទដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រទានដល់ព្រះថេរមួយអង្គឈ្មោះ វក្កលិ ថា៖

-ម្នាលវក្កលិ, អ្នកណាមើលឃើញនូវធម៌ អ្នកនោះឈ្មោះថា មើលឃើញនូវអញតថាគតដែរ, អ្នកណាមើលឃើញនូវអញតថាគត អ្នកនោះឈ្មោះថា មើលឃើញនូវធម៌ដែរ។

មើលឃើញទីនេះសំដៅយក មើលឃើញដោយបញ្ញាចក្ខុ ពោលគឺត្រិះរិះពិចារណានូវអត្ថនៃព្រះធម៌ដ៏ច្បាស់លាស់។

ម៉្យាងទៀត ក្នុងមហាបរិនិព្វានសូត្រដដែល មានសេចក្ដីតំណាលថាកាលដែលព្រះសម្ពុទ្ធ ទ្រង់សម្ដេចនូវសីហសេយ្យាផ្អៀងទៅខាងស្ដាំ ដោយយកព្រះបាទឆ្វេង តម្រួតលើព្រះបានស្ដាំ បែរព្រះសិរ្សទៅខាងឧត្តរទិស លើបរិនិព្វានមញ្ចាសនៈ ដែលព្រះអានន្ទរៀបចំថ្វាយក្នុងចន្លោះនៃសាលព្រឹក្សទាំងគូ។ ក្នុងគ្រានោះឯង ព្រះអង្គមានពុទ្ធតម្រាស់ថា៖

-ម្នាលអនន្ទ, បុគ្គលណាមួយ ទោះជាភិក្ខុក្ដី ភិក្ខុនីក្ដី ឧបាសកក្ដី ឧបាសិកាក្ដី, បានប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីកោតក្រែង ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី បុគ្គលនោះឈ្មោះថា ធ្វើសក្ការៈ គោរពរាប់អាន បូជានូវអញតថាគត ដោយគ្រឿងបូជាដ៏ឧត្ដម។

ព្រះពុទ្ធភាសិតខាងលើនេះ គឺព្រះអង្គចង់ឲ្យមនុស្សទូទៅប្រព្រឹត្តនូវសេចក្ដីល្អ បើយើងម្នាក់ៗ ធ្វើល្អឈ្មោះថា យើងពិតជាពុទ្ធសាសនិកពេញលក្ខណៈ។

ដើម្បីកុំឲ្យវែងពេក សូមមិត្តអ្នកណាក្រេបនូវព្រះពុទ្ធភាសិតសំខាន់ៗខ្លះ ដែលមានក្នុងព្រះត្រៃបិតកៈ

## ធម៌ ៥ យ៉ាង ដែលជាមូលហេតុនាំឲ្យ ព្រំសទ្ធម្មមិនបាត់បង់សាបសូន្យ

● ពុទ្ធបរិស័ទទាំងឡាយ ប្រុងត្រងត្រាប់ស្ដាប់ធម៌ដោយគោរព គឺដោយយកចិត្តទុកដាក់ ប្រុងស្មារតីមិនធ្វេសប្រហែស។

● សិក្សារៀនទន្ទេញធម៌ដោយគោរព គឺប្រុងដោយស្មារតីមិនធ្វេសប្រហែស។

● ទ្រង់ចងចាំនូវធម៌ ដែលបានរៀនហើយ ដោយគោរពគឺដោយប្រុងស្មារតីឥតធ្វេសប្រហែស។

● ប្រឹងគិត ពិចារណាឲ្យយល់នូវសេចក្ដីនៃធម៌ទាំងឡាយ ដែលខ្លួនបានចងចាំហើយ ដោយគោរព គឺដោយប្រុងស្មារតីពុំមានធ្វេសប្រហែស។

● ក្រោយដែលបានដឹងធម៌ ដឹងសេចក្ដីនៃធម៌ហើយ ខំប្រតិបត្តិធម៌ សមគួរដល់ធម៌ ដោយគោរព គឺដោយយកចិត្តទុកដាក់ ប្រុងស្មារតីឥតធ្វេសប្រហែស។

## ធម៌ ៥ យ៉ាង ដែលជាមូលហេតុនាំឲ្យ ព្រំសទ្ធម្មដល់នូវអន្តរធានសាបសូន្យបាត់បង់ទៅ

– (ពុទ្ធបរិស័ទ) មិនត្រងត្រាប់ស្ដាប់ធម៌ដោយគោរព
– មិនសិក្សារៀនទន្ទេញធម៌ ដោយគោរព
– មិនទ្រទ្រង់ចងចាំធម៌ ដោយគោរព

– មិនគិតពិចារណាឲ្យយល់សេចក្ដីនៃធម៌ទាំងឡាយ ដែលខ្លួនបានចងចាំហើយ ដោយគោរព

– ក្រោយដែលបានដឹងធម៌ ដឹងសេចក្ដីនៃធម៌ហើយ មិនប្រតិបត្តិធម៌សមគួរដល់ធម៌ ដោយគោរព។

X X X

ព្រះអង្គបានរំលឹកព្រះភិក្ខុសង្ឃដែលគង់ចាំវស្សានៅក្នុងអារាមមួយ នាវេឡុវគ្រាម ថា៖

● អ្នកទាំងឡាយ ចូរយកខ្លួនជាទីពឹង ចូរយកខ្លួនជាទីរលឹក កុំយកអ្វីដទៃជាទីរលឹកឡើយ, ចូរយកធម៌ជាទីរលឹក ចូរយកធម៌ជាទីពឹង កុំយកអ្វីដទៃជាទីរលឹកឡើយ។

X X X

ព្រះពុទ្ធតម្រាស់ក្នុងសង្ឃសន្និបាត នៃក្រុងវេសាលី ដើម្បីប្រកាសអំពីបរិនិព្វានកាលរបស់ព្រះអង្គថា

● ជនទាំងឡាយណា ទោះបីក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី ស្ដុកស្ដម្ភក្ដី ទ័លក្រក្ដី ជនទាំងឡាយនោះសុទ្ធតែមានសេចក្ដីស្លាប់នៅពីមុខទាំងអស់។

● ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះតូចក្ដី ធំក្ដី ឆ្អិនក្ដី ឆៅក្ដី ទាំងអស់សុទ្ធតែមានការបែកជាទីបំផុត យ៉ាងណាមិញ, ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ។

● **វ័យអញ** តថាគត ចាស់ណាស់ហើយ, ជីវិតអញតថាគតនៅតិចណាស់, អញតថាគតនឹងលះបង់នូវអ្នកទាំងអស់គ្នាហើយទៅ, រីឯទីពឹងរបស់ខ្លួន អញតថាគតបានធ្វើរួចហើយ។

● **ម្នាលភិក្ខុទាំងឡាយ**, អ្នកទាំងឡាយ ចូរកុំប្រហែសធ្វេស ចូរមានស្មារតី

មានសីលល្អបរិសុទ្ធ មានតម្រិះខ្ជាប់ខ្ជួនល្អ ចូររក្សាចិត្តរបស់ខ្លួនឲ្យល្អ។

● **ភិក្ខុណា** មិនប្រហែលធ្វេសក្នុងធម៌វិន័យនេះ ភិក្ខុនោះនឹងលះបង់នូវជាតិសំសារ ហើយនឹងធ្វើនូវទីបញ្ចប់នៃទុក្ខបាន។

ពុទ្ធភាសិតចុងក្រោយបំផុត គឺពេលហៀបនឹងបរិនិព្វានជាពុទ្ធភាសិតដែលពុទ្ធបរិស័ទទាំងឡាយ ត្រូវចងចាំគ្រប់គ្នាថា៖

● ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ.

-ហ៎ ឥឡូវនេះ, ភិក្ខុទាំងឡាយ! អញតថាគតហៅអ្នករាល់គ្នាមកប្រាប់, សង្ខារទាំងឡាយ សុទ្ធតែមានការអស់ទៅ សោះសូន្យទៅជាធម្មតា, អ្នកទាំងឡាយចូរញុំាងកិច្ចការដែលត្រូវធ្វើ ឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ!

នេះជាបច្ឆិមពុទ្ធវចនៈ គឺព្រះបរមពុទ្ធោវាទជាចុងក្រោយបំផុត។ ពុទ្ធភាសិតទាំងប៉ុន្មាន ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ក្នុងពេលហៀបនឹងបរិនិព្វានដែលបានស្រង់យកមកនេះ ជាពុទ្ធភាសិតមានអត្ថរស មានសារប្រយោជន៍ឧដុង្គឧត្តមណាស់ គួរពុទ្ធបរិស័ទទាំងឡាយ សិក្សាទន្ទេញឲ្យចាំហើយគិតពិចារណា ឲ្យយល់សេចក្ដីនៃពុទ្ធភាសិតទាំងនោះឲ្យច្បាស់លាស់ ដើម្បីទុកជាគោលគំនិតសំរាប់ពិចារណា ទុកជាផ្លូវសម្រាប់ប្រតិបត្តិ ដើម្បីឲ្យបានសម្រេចនូវសុខសន្តិភាពក្នុងបច្ចុប្បន្នជាតិ និងក្នុងអវសានជាតិ ពីព្រោះជាព្រះបរមពុទ្ធោវាទដែលគួរយើងជាពុទ្ធសាសនិកជន នឹកអាណោចអាធ័មឆ្ពោះទៅរកព្រះអង្គ ជាព្រះបរមសាស្ដាវិសេសវិសុទ្ធ ដែលគ្រាន់តែផុតអស់បណ្ដាំប៉ុណ្ណោះហើយ ទេពតា មនុស្សទាំងឡាយក៏លែងបានឮ លែងបានស្ដាប់ព្រះមធុរវាចាដែលលាន់ឮ ពីព្រះពុទ្ធឱស្ឋនោះសូន្យសោះទៅហើយ នៅបានឮត្រឹមតែព្រះត្រៃបិដក ដែលនៅរស់រវើកជាតំណាងព្រះអង្គ អស់រយៈកាលគម្រប់ ២៦ ពុទ្ធសតវត្សរ៍ គឺ ២៥១២ឆ្នាំ ដែលយើងសម្គាល់ថា ដូចព្រះអង្គមានព្រះជន្មនៅដរាបមកដល់សម័យយើងសព្វថ្ងៃនេះ យើងគួរគោរពព្រះត្រៃបិដក ១១០ភាគ

ជាតំណាងព្រះអង្គ ព្រះអរហន្តសម្មាសម្ពុទ្ធបរមគ្រូ!

ស្រង់ចេញពីសៀវភៅ ពិធីសម្ពោធព្រះត្រៃបិដក និង ព្រះពុទ្ធភាសិតខ្លះក្នុងបរិនិព្វានកាល ដែលសម្ដេចព្រះសង្ឃនាយក ហួត-តាត វជិរប្បញ្ញោ រៀបរៀង និងសម្ដេចព្រះសង្ឃរាជគណៈមហានិកាយ ជួន-ណាត ជោតញ្ញាណោ បានជួយពិនិត្យផ្ទៀងផ្ទាត់ផង ដើម្បីចែកជាធម្មទានក្នុងឱកាសនោះ កាលពីថ្ងៃ ១៤ កើត ខែចេត្រ ឆ្នាំរក សម្រិទ្ធិស័ក ព.ស.២៥១២ ត្រូវនឹងថ្ងៃទី១ មេសា គ.ស.១៩៦៩ ។

ចូរយើងជាខ្មែរចងចាំទុកថា ខ្មែរបានប្រែព្រះត្រៃបិដកចប់មុនគេ ក្នុងចំណោមប្រទេសអ្នកកាន់ពុទ្ធសាសនាក្នុងលោក។ ការប្រែមកជាខ្មែរនេះប្រើពេលអស់ ៤០ឆ្នាំគត់ គឺតាំងពី ព.ស. ២៤៧៣ (គ.ស. ១៩២៩) ដល់ ព.ស. ២៥១៣ (គ.ស. ១៩៦៩) ទើបចប់សព្វគ្រប់។

គោលបំណងនៃអ្នកប្រាជ្ញខាងសាសនា ជាពិសេសព្រះសង្ឃដែលជំនុំគ្នាប្រែព្រះត្រៃបិដកនេះ ដោយលោកយល់ឃើញថា "បើសូធ្យតាមបាលីនោះមុខជាគ្មានផ្ដល់ផលប្រយោជន៍អ្វីដល់ពុទ្ធបរិស័ទឡើយ ព្រោះពុំចេះភាសាបាលី មិនអាចដឹងអត្ថរសនៃព្រះពុទ្ធវចនៈដ៏មានខ្លឹមសារជាដាច់ខាត។ ការស្ដាប់មិនបាននេះហើយ ដែលធ្វើឲ្យប្រជាជនភាគខ្លះ ហ៊ានពោលបដិសេធថា «ព្រះពុទ្ធសាសនាគ្មានឃើញអ្វីសំខាន់ទេ» ..... " ចំណុចដ៏សំខាន់នេះហើយ ទើបព្រះសង្ឃដែលយល់ច្បាស់នូវព្រះពុទ្ធបំណង ខិតខំទម្លាយអាថ៌កំបាំង នៃពុទ្ធវចនៈ ដើម្បីឲ្យអ្នកផងឃើញ និងមានចិត្តស្រលាញ់-គោរព-ប្រតិបត្តិ ព្រះសាសនានេះកាន់តែខ្លាំងឡើងៗ កុំឲ្យភ័ន្តប្រទ្បំទៀត។

X X X

# គុណសោភកថា

(បទកាកគតិ)

យើងខ្ញុំបង្គំ
ក្រួញក្រាបប្រណម្យ ក្រោមព្រះបាទា នៃអង្គសម្ដេច
ព្រះសង្ឃរាជា អគ្គមេធា មហាវីរៈ។

កំពូលអ្នកប្រាជ្ញ
ព្រះទ័យអង់អាច វាងវៃប្រត្យក្ស ទាំងអក្សរសាស្ត្រ
ទាំងពុទ្ធចក្រ ទ្រង់ជាឯកអគ្គ[1] អ្នកបដិវត្ត។

រៀបរៀងធម៌អាថ៌
វិន័យសិក្ខា ដែលមានភ្លាំងភ្លាត់ ឲ្យបានត្រឹមត្រូវ
ត្រង់ដូចបន្ទាត់ ព្រះសង្ឃរាល់វត្ត ប្រតិបត្តិសិក្សា។

អក្សរសាស្ត្រជាតិ
ព្រះអង្គខ្មីឃ្មាត សង្វាតរចនា សើរើរៀបរៀង
ផ្ទៀងផ្ទាត់ភាសា ឲ្យមានលក្ខណា ថ្លៃថ្លាពីសី។

ទោះមានឧបសគ្គ
ពើបពះគ្រោះថ្នាក់ បង្អាក់ម្ដេចក្ដី ព្រះអង្គឥតរា
ពុះពារឃ្មាតខ្មី ប្រយោជន៍ដើម្បី សិរីខេមរា។

ប្រកបព្រះគុណ
គុណគាប់មហាធ្ងន់ ធ្ងន់ឥតឧបមា ទាំងផែនការជាតិ
ទាំងផ្នែកសាសនា ទ្រង់ព្រះឧស្សាហ៍ ពុំមានរសាយ។

ទោះទ្រង់ជរា
តែត្រង់ការងារ ពុំមានជិនណាយ ឥតទ្រង់តម្រិះ

---

១ អានថា «ឯកអាក់» ។

ដល់ព្រះអង្គកាយ ព្រះទ័យខ្វល់ខ្វាយ នឹងជាតិសាសនា។
កិច្ចការឧត្តម
ដែលទ្រង់ខិតខំ ប្រើព្រះប្រាជ្ញា បំពេញទុកឲ្យ
អ្នកក្រោយសិក្សា មានច្រើនប្រការ ហួសនឹងអធិប្បាយ។
ព្រះទ័យមេត្តា
អាសូរករុណា មនុស្សសត្វទាំងឡាយ ស្មោះស្មើទូទៅ
ទោះនៅជិតឆ្ងាយ គ្រប់ក្រុមនិកាយ ស្រស់ស្រាយរាក់ទាក់។
ឥឡូវព្រះអង្គ
ប្រសើរសីលទ្រង់ ឯកអង្គអគ្គៈ ទ្រង់ទិវង្គត
រលត់ជន្មជាក់ ខានយល់ព្រះភ័ក្ត្រ ព្រះអង្គទៀតហើយ។
ពីថ្ងៃនេះទៅ
យើងខ្ញុំរស់នៅ សោកសៅឥតស្បើយ អាឡោះអាល័យ
ម្ចាស់ថ្លៃខ្ញុំអើយ[២] ពីនេះទៅហើយ ខានយល់ភក្ត្រា។
ខានត្រង់ខានត្រាប់
ខានឮខានស្ដាប់ ព្រះរាជឱង្ការ ឮតែសូរសៀង
ស័ព្ទព្រះវាចា តាមឃោសនាការ ពីអក្សរសាស្ត្រ។
ដែលទ្រង់បរិយាយ
ពន្យល់ដោះស្រាយ ដោយក្ដីវៃឆ្លាស វែកញែកហេតុផល
ផ្ដល់ន័យប្រកាស ដោយព្រះតម្រាស់ ជាក់ច្បាស់ក្បោះក្បាយ។
ព្រះកាយបាត់ទៅ
ព្រះកេរ្ដិ៍គង់នៅ ឲ្យយើងទាំងឡាយ រៀនសូត្រសិក្សា
ភ្លឺថ្លាពណ្ណរាយ នឹកឡើងសែនស្ដាយ ស្ដាយឥតឧបមា។
ឱអម្ចាស់ថ្លៃ

---

២ អានថា «ខ្ញុំម្ម៉ើយ» ។

យើងខ្ញុំអាល័យ អាឡោះសោកា រន្ធត់តក់ស្លុត
ស្រយុតចិន្ដា ក្ដួលក្ដៅខ្លោចផ្សា ពុំមានស្រាកស្បើយ។

អ្នកនិពន្ធ
ព្រឹទ្ធបាលឯក ជា-ប៉ូរ

ធ្វើការនៅអគ្គសេនាធិការយោធពលខេមរភូមិន្ទ ក-៥

កំណត់ = កំណាព្យនេះកញ្ញា អ៊ឹំ-មន្ថា និងសហជីវិន រស់-លង និស្សិតនៃសាកលវិទ្យាល័យ វិចិត្រសិល្បៈសូធ្យរាល់ថ្ងៃសុក្រ តាមសម្លេងសមាគមអ្នកនិពន្ធខ្មែរ។

# កំណាន់មរណទុក្ខនានា

សម្តេចប្រសូតនៅថ្ងៃអង្គារ ១១ រោច ខែផល្គុន ឆ្នាំវក ឆស័ក ព.ស. ២៤២៧ (១១ មីនា ១៨៨៣) នៅភូមិកំរៀង សង្កាត់រកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ញោមប្រុសនាម «ជួន» និងញោមស្រីនាម «យក់» ជាកសិករ។ ព្រះអង្គមានប្អូនប្រុសមួយនាម ឧកញ៉ាសោភណមន្ត្រី «ជួន នុត» (ស) ។

ព្រះអង្គសោយព្រះទិវង្គត កាលពីថ្ងៃ ១៤ កើត ខែភទ្របទ ឆ្នាំរកា ឯកស័ក ព.ស. ២៥១៣ ត្រូវនិងថ្ងៃទី២៥ កញ្ញា ១៩៦៩ វេលាម៉ោង ២០ និង ២០ នាទី នៅក្នុងមហាកុដិព្រះអង្គនាវត្តឧណ្ណាលោម ដោយជរាពាធនិងដោយបំពេញកិច្ចការផ្សេងៗជាច្រើន មានអក្សរសាស្ត្រ សាសនា ។ល។

មុនពេលព្រះអង្គសោយទិវង្គត មានគ្រូពេទ្យ និងសិស្សានុសិស្សជាច្រើនបានក្រាបថ្វាយបង្គំសូមអង្វរសម្តេច សូមព្រះមេត្តាកុំធ្វើការច្រើនម៉ោងពេក តែព្រះអង្គមិនអាចលះបង់ទម្លាប់នោះបានឡើយ ដោយព្រះអង្គទ្រង់យល់ឃើញថា៖

«ខ្លួនយើង មើលមិនឃើញទេ ប៉ុន្តែយើងត្រូវខំប្រឹងធ្វើការឲ្យមានប្រយោជន៍ ដោយកាន់ចិត្តថា យើងមានជីវិតនៅរាប់ពាន់ឆ្នាំតទៅទៀត»

សេចក្តីសង្វេបថ្លែងមរណទុក្ខ នៃគណៈប្រតិភូនានា៖

● បពិត្រសម្តេចសង្ឃរាជជាអម្ចាស់!

ទូលព្រះបង្គំទាំងឡាយ ដែលជាកូនចៅព្រះអង្គ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ មានវិយោគទុក្ខ រន្ធត់ចិត្តឥតឧបមា ដោយគ្រាន់តែឮថា ព្រះអង្គសោយទិវង្គតភ្លាមៗ យើងខ្ញុំព្រះអង្គ ហាក់ដូចជាបាត់វិញ្ញាណ បាត់ស្មារតី រសេះរសោះអស់ទីពំនឹង ទីជម្រក,

● ព្រះអង្គជាអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមនៃពុទ្ធសាសនិកជន ក្នុងមណ្ឌលកម្ពុជរដ្ឋ និងជាអគ្គមហាបណ្ឌិតខ្មែរក្នុងពុទ្ធសតវត្សទី ២៥;

● ពិតមែនតែព្រះរូបសម្ដេចបានរលត់ទៅហើយក៏ដោយ ក៏ព្រះបរមកិត្តិនាម ព្រះរាជឱវាទនៃល្អងធូលីព្រះបាទ បានផ្ដិតជាប់នៅក្នុងហឫទ័យរបស់ទូលព្រះបង្គំយើងខ្ញុំជានិច្ចអស់កប្បាវសាន។

តម្កល់ទុកតាមច្បាប់លេខ ៧៦ ចុះថ្ងៃទី ២៤-២-១៩៧០
ប.ព. ទី ១ ចំនួន ១៥០០ ក្បាល

បោះនៅរោងពុម្ព ស៊ីន-មុយ លេខ ៣៤៥ វិថីកម្ពុជាក្រោម

X X X X X

វាយឡើងវិញដោយ៖ ទេព សុវិចិត្រ

- http://it4ug.net/
- http://sovichetlife.wordpress.com/

បានកែតម្រូវពាក្យខុសឲ្យត្រូវទៅតាមវចនានុក្រមខ្មែរ។

បានផ្ដល់ឯកសារដោយ៖ លោក ពិ ប៊ុន្នីន

- http://buddhistbibliography.com

ធ្វើនៅ ភ្នំពេញ, ថ្ងៃ ១៤ កើត ខែចែត្រ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥
ត្រូវនឹង, ថ្ងៃព្រហស្បតិ៍ ទី៥ ខែមេសា គ.ស. ២០១២